# កន្លែងល្បីៗនៃប្រទេសកម្ពុជា

## Famous places of Cambodia

TOP TRAVEL DESTINATIONS FOR 2022



LECTURE SENG PISETH

**រៀបរៀងនិងចងក្រង**


ដោយៈ

ក្រុមនិស្សិត IT ជំនាន់ទី ១៩ ឆ្នាំទីពីរនៃវិទ្យាស្ថានស៊ីតិក

ក្រុម SS3

- អាត   សិរីរ៉ុប
- ឈួរ   ប៉េងហួរ
- ខេមភារតនៈ
- ប៊ិន   លីហ័រ


ព.ស.២៥៥៦

គ.ស.២០២២

# មាតិកា

1. ខេត្ត សៀមរាប 2

1.1 ប្រាសាទអង្គរវត្ត 2

1.2 លក្ខណៈពិសេស 2

1.3 ប្រាសាទអង្គរវត្ត 3

2. ភ្នំពេញ 4

1.1 ព្រះបរមរាជវាំង 4

1.2 ប្រវត្តិនៃព្រះបរមរាជវាំង 4

1.3 សារមន្ទីរជាតិ 5

1.4 ប្រវត្តិសារមន្ទីរជាតិ 5

3. ខេត្ត ព្រះវិហារ 8

1.1 ប្រាសាទព្រះវិហារ 8

1.2 ប្រវត្តិប្រាសាទព្រះវិហារ 8

4. ខេត្ត កោះកុង 10

1.1 កោះស្ដេច វីសត 10

1.2 ទឹកធ្លាក់ ស្ទឹងពង្រួល 10

1.1 កោះស្ដេច វីសត 11

5.ខេត្ត រតនគិរី 12

1.1 បឹងយក្សឡោម 12

1.2 ទឹកជ្រោះ កាទៀង 13

1.3 ឧទ្យានជាតិវីរៈជ័យ 13
6. ខេត្ត មណ្ឌលគិរី 14
1.1 រមណីយដ្ឋាន ដំណាក់ស្តេច 14
1.2 ភ្នំដោះក្រមុំ 14
1.3 សួនសត្វ អូទ្រីស 15
1.4 ទឹកជ្រោះ ប៊ូស្រា 15
7. ខេត្ត ក្រចេះ 17
1.1 កោះផ្តៅ 17
1.2 អន្លង់ជ្រៀត 17
1.3 ភ្នំសំបុក 18
8. ខេត្ត ពោធិ៍សាត់ 21
1.1 ភ្នំ១៩០០ 21
1.2 ទឹកធ្លាក់ ថ្មដាតូច 21
1.3 វត្តភ្នំបាក់ត្រា 22
9. ខេត្ត បាត់ដំបង 23
1.1 ប្រាសាទភ្នំបាណន់ 23
1.2 តំបន់អភិរក្សដងទុង 24
1.3 ទឹកធ្លាក់ភ្នំ 53 25
10. ខេត្ត បន្ទាយមានជ័យ 26
1.1 ប្រាសាទបន្ទាយឆ្មារ 26
1.2 រមណីយដ្ឋាន អាងជើងគ្រុស 27

11. ខេត្ត កំពង់ចាម 28

1.1 ភ្នំប្រុសភ្នំស្រី 29

1.2 នគរបាជ័យ 30

1.3 រមណីយដ្ឋានបឹងធំ 30

12 ខេត្ត កំពង់ឆ្នាំង 32

1.1 ប្រាសាទប្រុស ឬប្រាសាទសក្ល 32

1.2 ប្រាសាទស្រី 33

1.3 សហគមន៍អេកូទេសចរណ៍ទឹកធ្លាក់ស្រែអំបិល 33

13 ខេត្ត កំពង់ស្ពឺ 34

1.1 ឧទ្យានជាតិគិរីរម្យ 34

1.2 អំពែភ្នំ 35

1.3 ខ្នងផ្សារ 35

14 ខេត្ត កំពង់ធំ 37

1.1 ប្រាសាទសំបូរព្រៃគុក 38

1.2 រមណីយដ្ឋានបឹងសិរីទ្ធិ 38

15 ខេត្ត កំពត 40

1.1 ទឹកធ្លាក់ឪម៉ាល់ 41

1.2 ឧទ្យានជាតិព្រះមុនីវង្ស បូកគោ 42

1.3 ចម្ការម្រេចភ្នំកូនសត្វ 43

16 ខេត្ត កណ្ដាល 44

1.1 ភ្នំព្រះរាជទ្រព្យ 44

1.2 ភ្នំប្រសិទ្ធិត្បូង........46
1.3 រមណីយដ្ឋានកៀនស្វាយក្រៅ........46
17 ខេត្ត ឧត្តរមានជ័យ........48
1.1 ប្រាសាទតាក្របី........48
1.2 អាតោដួងចិត្ត........49
1.3 ទឹកធ្លាក់ អូរស្វាយ........50
18 ខេត្ត ប៉ៃលិន........51
1.1 រមណីយដ្ឋានទឹកធ្លាក់អូរតាវៅឬទឹកធ្លាក់ភ្នំខៀវ........51
1.2 រមណីយដ្ឋានកែច្នៃ រហាត់ទឹក........51
19 ខេត្ត ព្រៃវែង........54
1.1 ចុងប៉មកន្លែងមើលថ្ងៃលិចស្អាតបំផុត........54
1.2 រមណីយដ្ឋាននគរភ្នំ(រមណីយដ្ឋានបាភ្នំ)........55
1.3 ប្រសាទព្រៃដើមស្រុក........56
20 ខេត្ត ស្វាយរៀង........57
1.1 រមណីយដ្ឋានប្រាសាទព្រៃបាសាក់........57
1.2 រមណីយដ្ឋានធម្មជាតិព្រៃគគីរ........58
1.3 ស្ពានព្រែកត្នោត........59
21 ខេត្ត តាកែវ........60
1.1 រមណីយដ្ឋានទេសចរណ៍ភ្នំដា........60
1.2 ប្រវត្តិរមណីយដ្ឋានទេសចរណ៍ភ្នំដា........60
1.3 ភ្នំតាម៉ៅ........61

22 ខេត្ត ត្បូងឃ្មុំ ............ 63
1.1 សហគមន៍ទេសចរណ៍ ............ 63
1.2 រមណីយដ្ឋានអន្លង់ជ្រៃ ............ 64
1.3 ត្នប់មទន្លេបិទ ............ 65
23 ខេត្ត ព្រះសីហនុ ............ 66
1.1 រមណីយដ្ឋានអន្លង់ជ្រៃ ............ 66
1.2 រមណីដ្ឋានឆ្នេរអូរឈើទាល ............ 66
1.3 ឆ្នេរសុខា ............ 67
1.4 កោះពស់ ............ 68

# 1. ខេត្ត សៀមរាប

## 1.1 ប្រាសាទអង្គរវត្ត



ប្រាសាទអង្គរវត្ត ឬប្រាសាទអង្គរតូចមានទីតាំងស្ថិតនៅ ភាគខាង ជើងនៃក្រុងសៀមរាបនៃខេត្តសៀមរាប។ ប្រាសាទអង្គរវត្តជាប្រាសាទព្រហ្មញ្ញសាសនាធំបំផុត និងជាវិមានសាសនាដ៏ធំបំផុតនៅក្នុងលោក។ ប្រាសាទនេះត្រូវបានកសាងឡើងដោយព្រះបាទសូរ្យវរ្ម័នទី២ ដែលជាស្នាដៃដ៏ធំអស្ចារ្យ និងមានឈ្មោះល្បីល្បាញរន្ទឺសុះសាយទៅគ្រប់ទិសទីលើពិភពលោក។ ប្រាសាទនេះសាងសង់ឡើងនៅដើមសតវត្សទី១២ ដែលស្ថិតនៅក្នុងរាជធានីយសោធរបុរៈ។ ប្រាសាទអង្គរវត្តជាប្រាសាទកសាងឡើង ដើម្បីឧទ្ទិសដល់ព្រះវិស្ណុ។ ប្រាសាទនេះជាប្រាសាទដែលនៅគង់វង្សល្អបំផុតនៅក្នុងតំបន់អង្គរ។ប្រាសាទអង្គរវត្ត ប្រើកម្លាំងពលកម្មប្រម៉ាណជាង 30ម៉ឺននាក់ និង ដំរី ជាង 6ពាន់ក្បាល និងប្រើប្រាស់ថ្ម សរុបប្រមាណជាង 10លានតោន។នៅក្នុងប្រាសាទមានចម្លាក់អប្សរាយ៉ាងស្អាត ចំណែកឯទីធ្លាខាងក្រៅមានដើមត្នោតរួមទាំងទេសភាពដ៏ស្រស់បំព្រង ហើយនៅជុំវិញប្រសាទ ប្រាសាទអង្គរវត្តត្រូវបានរចនាដើម្បីតំណាងភកនំព្រះសុមេរុ ដែលជាទីលំនៅរបស់អាទិទេព និងទេវតាក្នុងទេវកថាហិណ្ឌូ ដែលមានកសិណា ឬគូទឹកព័ទ្ធជុំវិញប្រហែលជា ១៦គីឡូម៉ែត្រ ចំណែកកសិណាពិតប្រាកដរបស់ប្រាសាទ មានបណ្ដោយប្រវែង ១៥០០ម៉ែត្រ x ទទឹង១៣០០ម៉ែត្រ លើ២០០ម៉ែត្រ ផ្លូវធំដើរចូលពីទិសខាងលិចទៅដល់ប្រាសាទកណ្ដាលមានប្រវែង ២៥០ម៉ែត្រ ឯកំពូលកណ្ដាលខ្ពស់ធំជាងគេបំផុតរបស់នគរវត្ត មានកម្ពស់ ៦៥ម និងជញ្ជាំងខាងក្រៅវែងគឺជាថែវមានបីជ្រុង ដែលថែវនីមួយៗឡើងខ្ពស់ទៅថែវដែលជាប់គ្នា។ នៅចំកណ្ដាលនៃប្រាសាទបញ្ឈរនូវជួរចតុរង្គនៃប៉ម។ មិនដូចប្រាសាទនៅតំបន់អង្គរភាគច្រើនទេ អង្គរវត្តបែរមុខទៅទិសខាងលិច តាមការស្រាវជ្រាវរបស់អ្នកសិក្សាបានវែកញែកថាជាចំណុចសំខាន់នៃប្រាសាទនេះ។ ប្រាសាទនេះត្រូវបានគេកោតសរសើរដោយសារភាពសម្បើម និងរុងរឿងនៃស្ថាបត្យកម្មនេះ ចម្លាក់ដែលលាតសន្ធឹង និងដោយសារស្ថាបត្យកម្មខ្មែរមានរូបអប្សរា និងទេវតា ដែលឆ្លាក់នៅលើជញ្ជាំងប្រាសាទ។

## 1.2 លក្ខណៈពិសេស

តាមការសន្និដ្ឋានរបស់អ្នកស្រាវជ្រាវ ប្រាសាទអង្គរវត្ត ប្រើកម្លាំងពលកម្មប្រម៉ាណជាង 30ម៉ឺននាក់ និង ដំរី ជាង 6ពាន់ក្បាល និងប្រើប្រាស់ថ្ម សរុបប្រមាណជាង 10លានតោន នៅក្នុងទំហំ ខ្នាត , និង ភាពស៊ីមេទ្រីឡើងដល់កំពូល ដែលត្រូវបាន គេជឿថាជាប្រាសាទសាសនា ដ៏ធំបំផុត របស់ពិភពលោក។ (អង្គរវត្តជាប់ជាស្ថាបត្យកម្មកំពូលក្នុងលោក)



- ប្រាសាទដែលបង្រួមឧបទ្វីបទាំងអស់បញ្ចូលគ្នា។
- រៀងរាល់ថ្ងៃទី21.22 ខែមីនា និងថ្ងៃទី 22.23 ខែកញ្ញា គឺព្រះអាទិត្យរះនិងលិចចំកណ្តាលកំពូលប្រាសាទអង្គរវត្ត ដែលចែករយៈពេល យប់ និង ថ្ងៃ ស្មើគ្នា (សមរាត្រី)
- គ្រប់អ័ក្សនៃប៉មរបស់ប្រាសាទ គឺកើតចេញពីរង្វង់មូលដែល តំណាងឲ្យហ្វូងតារា ត្រាគោ (Draco) កញ្ចុំសកលដែលមានអាយុកាល2លានឆ្នាំ ដែលមានចម្ងាយពីផែនដី 19ទ្រីលានគីឡូម៉ែត្រ ដោយស្មើនិងរង្វាស់កាំរស្មីព្រះអាទិត្យ 2ឆ្នាំពន្លឺ ។
- ប្រាសាទអង្គរវត្តមាន រាងចុះអ័ក្ស 3 ជាន់ជាប់ៗគ្នាបើធៀបនឹងផ្ទៃទឹកបារាយ (បច្ចុប្បន្នបារាយខាងកើតត្រូវបានរីងស្ងួត) អ័ក្សទាំង3 ប្រៀបដូចជា រាងផ្កាយរណបដែលសំយោគយកថាមពលព្រះអាទិត្យដែលបានបាញ់បង្ហោះនៅពេលបច្ចុប្បន្ន។
- គ្រឹះប្រាសាទធ្វើអំពីដីខ្សាច់ ដែលពឹងលើគូទឹកដែលព័ទ្ធជុំវិញប្រាសាទទាំងស្រុង។
- គ្រប់ប៉មនៃអង្គរវត្តជាចំនុចដែលបង្កើតរាងជាសត្វអណ្តើកដែលទាក់ទងនិងរឿងកូរសមុទ្រទឹកដោះ ឬ កូរសមុទ្រចក្រវាឡ ។
- អង្គរវត្ត ស្ថិតនឹងខ្សែអ័ក្សទី7 នៃរយៈទទឹងរបស់ផែនដីដែលខ្សែរនោះជាន់គ្នាជាមួយនឹង ប្រាសាទពីរ៉ាមីត ជីហ្សា របស់អេស៊ីប ប្រាង្គតឹកឈេនអ៊ីតសា របស់ម៉ិចស៊ិច និងចុងក្រោយជាមួយរូបសំណាកមនុស្សបុរេប្រវត្តិ របស់ឈីលី ។
- អង្គរវត្តមានលក្ខណៈពិសេសមួយគឺប្រែពណ៌ពីសំរិទ្ធទៅប្រាក់ ពីប្រាក់មកមាស ទៅតាមពេលវេលាមួយទៀងទាត់ ព្រឹក ថ្ងៃ និង រសៀល។
- អង្គរវត្តមានរូបភាពលាក់បង្កប់ច្រើនជាង 200 ផ្ទាំងដែលមិនអាចមើលដឹងដោយភ្នែកទទេបាន ត្រូវជំនួយដោយបច្ចេកវិទ្យា Scan Effect
- អ្នកស្រាវជ្រាវបានឲ្យដឹងទៀតថា ប្រាសាទអង្គរវត្ត មានតម្លៃទាំងផ្នែកបញ្ញា ផ្នែកស្ថាបត្យកម្មនិងសម្បត្តិវប្បធម៌។
- អង្គរវត្តជាស្ថាបត្យកម្មបានទទួលការគណនានិងធ្វើឡើងយ៉ាងសុក្រឹត្យបំផុតនៅលើពិភពលោក។
- ក្រុមអ្នកស្រាវជ្រាវនៅតែចោទជាសំនួរទៅកាន់ប្រាសាទដ៏អស្ចារ្យក្នុងលោកនេះ។

## 1.3 ប្រាសាទអង្គរវត្ត

មានចំណាងជើងជាផ្លូវការថា "ផ្លូវលេខ 8" Pub Street គឺជាមជ្ឈមណ្ឌលនៃសកម្មភាពនៅពេលរាត្រីនៅក្នុងខេត្តសៀមរាប។ ផ្លូវដែលចាប់ផ្តើមពីភោជនីយដ្ឋាន Red Piano និងបញ្ចប់នៅភោជនីយដ្ឋានស្ទឹកចេក គឺជាផ្លូវប្រវែង 100 ម៉ែត្រ ដែលពោរពេញដោយពន្លឺភ្លើងអ៊ីយូតា ក្លឹបបារ ភោជនីយដ្ឋាន និងអាជីវករ។

ស្ថិតនៅចំកណ្តាលទីក្រុង ក្បែរមាត់ស្ទឹងសៀមរាបដ៏ស្រស់ស្អាត និងផ្សារផ្សេងៗ ផាប់ស្ទ្រីត គឺជាកន្លែងដែលអ្នកធ្វើដំណើរពីជុំវិញពិភពលោកមកជួបជុំគ្នារាំលេងពេលរាត្រី។ វាអាចត្រូវបានគេគិតថាជាកំណែដ៏ស្រស់ស្អាតនៃផ្លូវ Khaosan ក្នុងទីក្រុងបាងកក ប៉ុន្តែក៏ជាការសប្បាយដែរ។ មកដល់ពេលយប់ ផ្លូវត្រូវបានបិទមិនឱ្យធ្វើចរាចរណ៍ ធ្វើឱ្យវាជាកន្លែងសម្រាកលំហែ និងមានសុវត្ថិភាពសម្រាប់ដើរ រាំ និងបន្ទូរអារម្មណ៍។ ជាមួយនឹងមុខម្ហូបជាច្រើនមុខ រាប់ចាប់ពីមុខម្ហូបពិសេសរបស់ខ្មែរ រហូតដល់ម្ហូបបែបបស្ចិមប្រទេស ដែលផ្តល់ជូនក្នុងរថយន្តដឹកអាហារ ស្រាបៀរស្ងួត 50 សេន និងអាហារសម្រន់សត្វល្អិតសម្រាប់ញ៉ាំ អ្នកអាចចំណាយពេលពេញមួយយប់របស់អ្នកនៅលើវិថីដ៏រស់រវើកនេះ និងមិនអស់ពីការផឹករដែលត្រូវធ្វើ។ .

# 2. ភ្នំពេញ



## 1.1 ព្រះបរមរាជវាំង

ព្រះបរមរាជវាំងនៃព្រះរាជាណាចក្រកម្ពុជា ឬព្រះបរមរាជវាំងចតុមុខមង្គល គឺជាព្រះរាជវាំងដែលជាទីប្រថាប់នៃព្រះមហាក្សត្រខ្មែរ តាំងតែរជ្ជកាលព្រះបាទនរោត្តម ព្រហ្មបរិរក្សបរមរាមាទេវតា រហូតរជ្ជកាលបច្ចុប្បន្នគឺព្រះបាទសម្ដេច ព្រះបរមនាថនរោត្តម សីហមុនី ។ ព្រះបរមរាជវាំងមានទីតាំងស្ថិតនៅកណ្ដាលរាជធានីភ្នំពេញ ក្បែរចំណុចប្រសព្វ នៃទន្លេ ធំទាំងបួនដែលគេហៅថាទន្លេចតុមុខ ដែលនេះគឺជាលក្ខណៈពិសេសនៃព្រះបរមរាជខ្មែរហើយក៏ជាបុព្វហេតុដែលគេ ប្រសិទ្ធនាមព្រះបរមរាជវាំងនេះថា ព្រះបរមរាជវាំងចតុមុខមង្គលផងដែរ។

## 1.2 ប្រវត្តិនៃព្រះបរមរាជវាំង

ព្រះបរមរាជវាំងចតុមុខមង្គលសំដៅលើព្រះបរមរាជវាំងដែលសាងនៅចំណុចប្រសព្វចតុមុខ រាជធានីភ្នំពេញសព្វថ្ងៃ។ ព្រះបរមរាជវាំងនេះមានការស្ថាបនាចំនួនពីរលើកធំៗរួចមកហើយ ដោយលើកដំបូងបំផុតត្រូវបានសាងសង់នៅក្នុងរជ្ជកាលព្រះបាទពញាយ៉ាត នាសម័យចតុមុខ ប៉ុន្តែត្រូវបានបោះបង់ចោលណៅពេលមានការផ្លាស់ប្ដូររាជធានីនាសម័យក្រោយ មកទៀត។ ការស្ថាបនាព្រះបរមរាជវាំងចតុមុខជាលើកទី២ត្រូវបានធ្វើឡើងក្នុងរាជ្យ ព្រះបាទនរោត្តម ដោយព្រះអង្គបាន ផ្លាស់ប្ដូររាជធានីពីក្រុងឧត្តុង្គមកកាន់ក្រុងភ្នំពេញវិញនៅក្នុងឆ្នាំ១៨៦៦ ហើយត្រូវបានសាងសង់បន្ថែមដោយរជ្ជកាលក្រោយៗ ទៀត ចាប់ពីរជ្ជកាលព្រះបាទស៊ីសុវត្ថិ រហូតមករជ្ជកាលបច្ចុប្បន្ននេះ។ ហេតុដែលព្រះរាជវាំងនេះមានឈ្មោះថា ព្រះបរមរាជវាំង ចតុមុខមង្គល ក៏ដោយសារតែព្រះបរមរាជវាំងនេះ ស្ថិតនៅត្រង់ចំណុចប្រសព្វនៃទន្លេធំទាំងបួន គឺទន្លេមេគង្គលើ ទន្លេមេគង្គក្រោម ទន្លេបាសាក់និងទន្លេសាប ហើយព្រះបរមរាជវាំង ត្រូវបានសាងសង់បែរមុខទៅកាន់ទិសខាងកើត ពោលគឺបែរមុខទៅរក

ព្រះបរមរាជវាំងមានកំពែង ព័ទ្ធជុំវិញប្រវែង ១៧៧២ម៉ែត្រ ដោយកំពែងខាងកើតប្រវែង ៤២១ម៉ែត្រ កំពែងខាងលិចប្រវែង ៤៣៥ម៉ែត្រ កំពែងខាងជើងប្រវែង ៤៨៤ម៉ែត្រ និងកំពែងខាងត្បូងប្រវែង ៤៣២ម៉ែត្រ។ កំពែងថ្មដែល លំអទៅដោយសន្ទឹកសីមាទាំងនេះត្រូវបានកសាងឡើងនៅឆ្នាំរវាង ១៨៦៦ដល់ឆ្នាំ១៨៧០ ក្នុងរជ្ជកាលព្រះបាទនរោត្តម។ ព្រះបរមរាជវាំងត្រូវបានកសាងតាមរចនាបថបាយ័ន ដែលមានក្លោងទ្វារចេញចូល ចំនួន៥ ហើយទ្វារទាំង៥នោះ ត្រូវបានគេសង់មិនឲ្យចាក់ចំគ្នាឡើយ។ នៅប្រាសាទបាយ័ន ក្លោងទ្វារជ័យនិង ក្លោងទ្វារខ្មោចស្ថិតនៅទិសខាងកើត ហើយក្លោងទ្វារខ្មោច ស្ថិតនៅខាងស្ដាំ ក្លោងទ្វារជ័យ។ ចំនែកឯព្រះបរមរាជវាំងចតុមុខមង្គលវិញ ក្លោងទ្វារជ័យ ស្ថិតនៅទិសខាងកើត ដែរតែក្លោងទ្វារខ្មោចវិញស្ថិតនៅឯទិសខាងជើងទៅវិញ។ ក្លោងទ្វារខ្មោចនេះត្រូវបានគេអនុញ្ញាតិអោយប្រើ តែពេលណាមានព្រះមហាក្សត្រចូលទីវង្គត ដើម្បីដង្ហែព្រះបរមសព ទៅថ្វាយព្រះភ្លើងនៅឯទីវាលមេរុ។ សំណង់ទាំងឡាយ ក្នុងព្រះបរមរាជវាំង ត្រូវបានគេកសាងឡើងទៅតាម ស្ថាបត្យកម្មប្រពៃណីជាតិដោយមានអ្នកឧកញ៉ាទេពនិម្មិត ម៉ក់ ដែលជាស្ថាបត្យករដ៏ឆ្នើមជាអ្នករៀបចំ។ ប្រាសាទជាច្រើន មានរាងសង្ហារ ទៅតាមក្បូរក្បាច់រចនា ហើយមានដំបូលច្រើនជាន់ ប្រក់ក្បឿងពណ៌មាស និងមានប្រាង្គកណ្ដាលសារពើសូត្រ កំពូលស្រួច

បាញ់ទៅលើ ដែលជា និមិត្តរូបនៃការរីកចម្រើនមិនចេះចប់។

ព្រះបរមរាជវាំង ត្រូវបានចាត់ទុកជាតំណាងប្រទេសជាតិទាំងមូល ហើយរាល់សំណង់ប្រាសាទនៅក្នុងព្រះបរមរាជវាំង ត្រូវបានគេលាបលំអដោយពណ៌លឿងតំណាងឲ្យព្រះពុទ្ធសាសនា និងពណ៌សដែលតំណាងឲ្យព្រហ្មញ្ញសាសនា។



## 1.3 សារមន្ទីរជាតិ

សារមន្ទីរជាតិនៅទីក្រុងភ្នំពេញជាសារមន្ទីរធំជាងគេនៅប្រទេសកម្ពុជា ដែលជាទីតាំងប្រមូលផ្តុំសម្បត្តិវប្បធម៌ និងប្រវត្តិសាស្រ្តដ៏សំខាន់។ សារមន្ទីរជាតិមានរក្សាទុករូបសំណាកនិងកស្តុតាងប្រវត្តិសាស្រ្តកម្ពុជា ចំនួនជាង១ម៉ឺន៤ពាន់ តាំងពីសម័យបុរេប្រវត្តិ សម័យអង្គរ និង សម័យក្រោយៗមកទៀត។




## 1.4 ប្រវត្តិសារមន្ទីរជាតិ

សារមន្ទីរជាតិនេះត្រូវបានកសាងនៅថ្ងៃ១៥សីហា១៩១៧ តាមរបៀបស្ថាបត្យកម្ម ប្រពៃណីខ្មែរ ហើយត្រូវបានសម្ពោធក្នុងឆ្នាំ១៩២០ ដោយព្រះបាទស៊ីសុវត្ថិ ។ នៅខាងក្នុងសារមន្ទីរជាតិមានតំកល់វត្ថុបុរាណសល់តាំងពីសម័យមុនអង្គរ និងសម័យអង្គរ ។ វាជាការប្រមូលថែរក្សាទុកដ៏ល្អសម្រាប់ពិភពលោកធ្វើការស្រាវជ្រាវអំពីវត្ថុបុរាណសិល្ប: សាសនាបុរាណវិទ្យាខ្មែរតាំងពីសតវត្សទី៤ រហូតដល់សតវត្សទី១៣។

លោក ហ្គក ហ្ក្រូសលីយេ (George Groslier) ស្ថាបនិកបង្កើតសារមន្ទីរជាតិកម្ពុជា

សារមន្ទីរជាតិត្រូវបានកសាងឡើងនៅក្នុងឆ្នាំ ១៩១៧ នាសម័យអាណានិគមបារាំងមកលើព្រះរាជាណាចក្រកម្ពុជា (១៨៦៣-១៩៥៣) ដែលមានស្ថាបត្យករ ជនជាតិបារាំងឈ្មោះហ្គកហ្ក្រូសលីយេ (George Groslier) ដែលមានបណ្តោយ៥៤ម៉ែត្រ និង ជម្រៅ៦៦ម៉ែត្រ ហើយសង់លើខឿនដែលមានកម្ពស់២ម៉ែត្រកន្លះ។ ពិធីសម្ពោធបានប្រព្រឹត្តិទៅ ថ្ងៃទី ១៣ ខែមេសា ឆ្នាំ១៩២០ ក្រោមព្រះរាជាធិបតីភាពរបស់ ព្រះករុណា ព្រះបាទស៊ីសុវត្ថិ ព្រះចៅក្រុងកម្ពុជា និង ចំពោះមុខលោក ហង់រី បូឡាំង អ្នកប្រចាំការជាន់ខ្ពស់បារាំងនៅកម្ពុជា។ កាលពីដំបូងឡើយសារមន្ទីរជាតិនេះមានឈ្មោះថា សារមន្ទីរក្រុងកម្ពុជាធិបតី ហើយដើម្បីលើកកិត្តិយសដល់លោកទេសាភិបាលបារាំងឈ្មោះ អាល់ប៊ែរ



សារូត៍ (Albert Sarraut) ទើបប្តូរឈ្មោះជាសារមន្ទីរអាល់ប៊ែរ សារូត។

សព្វថ្ងៃមានការតាំងផ្ទាកពីរ ធ្វើអំពីថ្មកែវមួយជា ភាសាខ្មែរ និង មួយទៀតជាភាសាបារាំងដែលគេចារិកតាំងពីជំនាន់នោះ។ បូង់សារមន្ទីរត្រូវបានគូរដោយលោក ហ្គកហ្ស៊ូសលីយេ (George Groslier) សមូហកម្មនៃក្បាច់ចម្លាក់របស់វិមានសុទ្ធសឹងជាស្នាដៃរបស់វិចិត្រករខ្មែរដែលជា គ្រូ និង ជា សិស្សរបស់សាលានេះដែលមានដូចជារឿងនាងកាកី ឬ រឿមកេរ្តិ៍ជាដើម ( កាលពីសម័យ នោះអាគារនោះជាសារមន្ទីរផងនិង ជាសាលាបណ្តុះបណ្តាលផង) ។ អ្នកទាំងនោះបានតុបតែងក្បាច់ចម្លាក់ដ៏រស់រវើកនៅលើបង្អួចទាំងដប់ពីរ និងទៅលើទ្វារធំទាំងបី ដែលបានគូរផ្តាំងគំនូរផ្សេងៗតាមរឿងព្រេងនិទានខ្មែរបុរាណតាមសន្ទឹកបង្អួចដួរខាងលិច (ពីខាងក្នុង)។

សារមន្ទីរជាតិស្ថិតនៅក្នុងមណ្ឌលតែមួយរបស់ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ខាងត្បូង (សង់ក្នុងឆ្នាំ១៩១៧) ប្រជាជនខ្មែរមានទម្លាប់ ហៅ មណ្ឌលនេះថា សាលារចនា។ សារមន្ទីរត្រូវបានគ្រប់គ្រងដោយអភិរក្សជនជាតិបារាំងមានជាអាទិ លោក ហ្សកហ្គ្រូសលីយេ ជាអភិរក្ស ទីមួយ ព្យែរឌុយប៉ុង (Pierre Dupont) ហើយ បន្ទមកទៀតការគ្រប់គ្រងសារមន្ទីរក៏ត្រូវបានប្រគល់ជូនទៅលោក សូឡង់ ធៀរីប៊ែរណា (Solange Thierry Bernard) ធ្វើជាចាងហ្វាង រហូតដល់ឆ្នាំ១៩៤៩។

បន្តបន្ទាប់មកទៀតក្នុងឆ្នាំ១៩៥០សារមន្ទីរ កាន់កាប់ដោយលោក Jean Boesselier ដែលជាអភិរក្សរងនៅអង្គរ ក៏បានទទួលការដឹកនាំនៅសារមន្ទីរវិញ។ លោកបាន រៀបចំការផ្ទេរអំណាចគ្រប់គ្រងសារមន្ទីរពីសាលាបារាំងចុងបូព៌ាមកជូនរាជរដ្ឋាភិបាលវិញ។ ពេលនោះហើយដែលសារមន្ទីរត្រូវប្តូរឈ្មោះមកជា សារមន្ទីរជាតិ នៃកម្ពុជា។ បន្ទាប់ពីលោក Jean Boesselier មកកញ្ញាម៉ាដឺឡែន ហ្ស៊ីតូ (Madeleine Giteau) (១៩៥៦-១៩៦៦) បានមកធ្វើជាអភិរក្សបន្ត ។

ចាប់តាំងពីឆ្នាំ ១៩៦៦ កិច្ចសន្យាដប់ឆ្នាំរវាងសាលាបារាំងចុងបូព៌ា និង រាជរដ្ឋាភិបាលកម្ពុជាត្រូវដល់កំណត់បញ្ចប់។ ការដឹកនាំគ្រប់គ្រងសារមន្ទីរជាតិ ត្រូវបានផ្ទេរ មកជូនអភិរក្សខ្មែរដំបូងបំផុត គឺលោកជា ថៃសេង (Chea Thay Seng) ដែលលោកធ្លាប់ទៅសិក្សានៅ(Ecole du Louvre) និងនៅសកលវិទ្យាល័យក្រុងប៉ារីសនា ប្រទេសបារាំង ។ លោក ជា ថៃសេង បានដឹកនាំសារមន្ទីរក្នុងឋានៈ ជាអភិរក្ស (ចាងហ្វាង) រហូតដល់១៩៧១ ។ បន្ទាប់មកលោក Ly Vouong ត្រូវបានតែងតាំងជា អភិរក្សបន្ត លោកទាំង ពីរនាក់ ត្រូវបានគេសម្លាប់ក្នុងរបបខ្មែរក្រហម។

នៅទសវត្សឆ្នាំ ១៩៧០ ដោយប្រទេសកម្ពុជាជួបនឹងវិបត្តិនយោបាយហើយ សន្តិសុខមិនជានាផងនោះ លោក Bernard Philippe Groshier ដែលជាអ្នកគ្រប់គ្រង ប្រាសាទអង្គរវត្ត ក៏បានដឹកជញ្ជូនវត្ថុដ៏មានតម្លៃពីអភិរក្សអង្គរខេត្តសៀមរាប មកកាន់សារមន្ទីរជាតិ។ វត្ថុសិល្បៈដ៏មានតម្លៃពីសារមន្ទីរទាំងពីរនៃខេត្តបាត់ដំបង និង សារមន្ទីរដទៃទៀតក៏ត្រូវបានជញ្ជូនមកទុកក្នុងសារមន្ទីរជាតិដែរ។

ក្រោយពីបិទទ្វារចោលក្នុងរបបខ្មែរក្រហមអស់រយៈពេលជិត ៤ឆ្នាំ សារមន្ទីរក៏បានរៀបចំឲ្យមានសណ្តាប់ធ្នាប់ និងបើកបម្រើជូនភ្ញៀវចូលទស្សនាជាថ្មីឡើងវិញនៅថ្ងៃទី ១៣ ខែមេសា ឆ្នាំ១៩៨០ អ្នកដែលមានសញ្ញាប័ត្រជាន់ខ្ពស់ចេញពីមហាវិទ្យាល័យត្រូវបានតែងតាំងឲ្យធ្វើជាប្រធាន ដឹកនាំគ្រប់គ្រងជាបន្តបន្ទាប់ដែលមានលោក អ៊ុ

កជា លោក អ៊ុកស៊ុនហេង។ តមកគឺលោកពេជកែវ (ពី ឆ្នាំ ១៩៩១-១៩៩៦) ។ នៅថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ១៩៩៦ មានពិធីផ្ទេរតំណែងរវាងលោក ពេជ កែវ និង លោក ឃុនសាម៉េន ក្រោមអធិបតីភាពឯកឧត្តមរដ្ឋមន្រ្តីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នុតណារាំងនៅសារមន្ទីរជាតិ។ តមកទៀតគឺលោកហាប់ ទូច និងចុងក្រោយគឺលោក គង់ វីរៈ មកដល់បច្ចុប្បន្ន។

កាលពីដំបូងសារមន្ទីរជាតិ ជាអាគារមួយស្ថិតនៅក្នុងអតីតវិទ្យាល័យព្រះស៊ីសុវត្ថិ ដែលមានឈ្មោះថា "សារមន្ទីរ ភ្នំពេញ" ។ នៅពេល ដែលសារមន្ទីរជាតិ (សារមន្ទីរ សព្វថ្ងៃ) ធ្វើការសាងសង់រួចហើយ ទើបសារមន្ទីរភ្នំពេញមកតាំងនៅ សារមន្ទីរជាតិសព្វថ្ងៃ ដោយប្រែឈ្មោះថា "សារមន្ទីរក្រុងកម្ពុជាធិបតី"។

ក្រោយពីថ្ងៃសម្ពោធក្នុងឆ្នាំ១៩២០ សារមន្ទីរក្រុងកម្ពុជាធិបតី ត្រូវបានប្តូរឈ្មោះជាៈ "សារមន្ទីរអាល់ប៊ែរសារ៉ូត៍"។ ហើយនៅឆ្នាំ១៩៩៦ បានប្តូរឈ្មោះជា "សារមន្ទីរ ជាតិនៃកម្ពុជា" ។ លុះមកដល់ឆ្នាំ១៩៧៩ សារមន្ទីរ ត្រូវបានប្តូរឈ្មោះជា : "សារមន្ទីរវត្ថុបុរាណ"។ បន្ទាប់មកក្នុងសម័យលោក ពេជ កែវជា អភិរក្សសារមន្ទីរត្រូវបាន ប្រែឈ្មោះថា "សារមន្ទីរជាតិនៃកម្ពុជា" រហូតដល់សព្វថ្ងៃនេះ។



# 3. ខេត្ត ព្រះវិហារ

## 1.1 ប្រាសាទព្រះវិហារ



ប្រាសាទព្រះវិហារមានទីតាំងនៅភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្ត នៅលើជួរភ្នំដងរែកជាប់ព្រំប្រទល់អន្តជាតិកម្ពុជានិងប្រទេសថៃ។ ប្រាសាទព្រះវិហារមានចំងាយផ្លូវ ៤០០គមពីភ្នំពេញ តាមផ្លូវជាតិលេខ៦២ និង១៥០គមពីទីរួមខេត្តព្រះវិហារ។ ប្រាសាទព្រះវិហារត្រូវបានកសាងឡើងក្នុងសម័យអង្គរដោយព្រះមហាក្សត្រព្រះបាទសូរ្យវរ្ម័នទី១ នៅក្នុងសតវត្សរ៍ទី១១ និងត្រូវបានកសាងដោយព្រះមហាក្សត្រជាច្រើនអង្គរទៀត។ ប្រាសាទព្រះវិហារមានឈ្មោះតាមសិវលិង្គនៅក្នុងប្រាសាទដែលមានឈ្មោះថា ស្រី សិខារិស្វរៈ ដែលមានន័យថាអំណាចនៃកំពូលភ្នំ។ សិវលិង្គដែលតម្កល់នៅក្នុងប្រាសាទនេះត្រូវបាននាំយកមកពីប្រាសាទវត្តភូ(ប្រទេសឡាវ)ដើម្បីតម្កល់ទុកនៅក្នុងប្រាសាទនេះ។ ប្រាសាទព្រះវិហារមានគោបុរៈ(ខ្លោងទ្វារ)ចំនួន៥ ដែលរៀបចំពីគោបុរៈទី១នៅខាងលើរហូតដល់គោបុរៈទី៥ ប្រាសាទព្រះវិហារបែរមុខទៅទិសខាងជើង។ ភ្នំនេះមានកំពស់៧៤០ម ធៀបកំពស់ទឹកសមុទ្រ។ ដោយមានផ្ទៃក្រលា៨០០ម៤០០ម ចំនោតខ្ទាំងពីទឹកដីកម្ពុជានិងរាងទេរទៅរកទឹកដីប្រទេសថៃ។ ប្រាសាទព្រះវិហារត្រូវបានដាក់បញ្ចូលក្នុងបញ្ជីជាសម្បត្តិបេតិកភណ្ឌពិភពលោកនៅថ្ងៃទី៧ខែកក្កដាឆ្នាំ២០០៨។

## 1.2 ប្រវត្តិប្រាសាទព្រះវិហារ

ក្រុមអ្នកបុរាណវិទ្យាតែងបានគិតថា ជាប្រាសាទដែលមានរបៀបសង់សឹងតែដូចៗគ្នាទៅនឹងសំណង់ដទៃទៀតដែលស្ថិតក្នុងស្ថាបត្យកម្មរបស់ស្តេចសូរ្យវរ្ម័ទី១ គឺបែបប្រាសាទសណ្តូកលើភ្នំ ចាំងច្រិតថ្មភ្នំសាងជាប្រាសាទដូចគ្នាទៅនឹងប្រាសាទវត្តភូ ប្រាសាទភ្នំជីសូរ ប្រាសាទដើងព្រៃ ប្រាសាទវត្តត្រាច....ជាដើម។ល។ វិចម្ញាក់នៅលើហោរជាងមានទំរង់ដូចនៅប្រាសាទបន្ទាយស្រី និង កោះកេរ ដូច្នោះដែរ ។តាមរយៈការសិក្សាស្រាវជ្រាវអាចសន្មតថាសំណង់ប្រាសាទព្រះវិហារត្រូវបានចាប់ផ្តើមកសាងឡើងដំបូងនៅដើមសតវត្សទី៩ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០)។ តាមរយៈសិលាចារឹកលេខ K-៥៨៣ នៅប្រាសាទបាពួន ចារក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័នទី២ (៨៤៤-៩៦៨) និយាយថាព្រះអម្ចាស់ឥន្ទ្រាយុទ្ធជាព្រះបុត្រារបស់ព្រះបាទជ័យវរ្ម័នទី២ បានទៅធ្វើតបៈនៅភ្នំលិង្គបព៌ត(ប្រាសាទវត្តភូចំប៉ាសាក់ប្រទេសឡាវ) ហើយបាននាំយកលិង្គព្រះឥសូរពីថ្មលិង្គភ្នំធម្មជាតិ (ស្វយម្ភូលិង្គ) មកតម្កល់នៅលើភ្នំព្រះវិហារក្នុងព្រះនាមអាទិទេព ព្រះស្រីសិខរីស្វរៈ ដែលមានន័យថាអាទិទេពនៃកំពូលភ្នំ។ ស្រីសិខរីស្វរៈនេះហើយដែលហៅចំពោះលិង្គព្រះឥសូរតម្កល់នៅប្រាសាទព្រះវិហារ និងជាឈ្មោះប្រាសាទព្រះវិហារសម័យបុរាណផង។ ប្រាសាទព្រះវិហារសាងសង់សម្រាប់ឧទ្ទិសចំពោះព្រះឥសូរ ក្នុងសាសនាព្រាហ្មណ៍។ ព្រះមហាក្សត្រខ្មែរដែលកសាងប្រាសាទព្រះវិហារមានដូចជា៖

- ព្រះអង្គម្ចាស់ឥន្ទ្រាយុទ្ធបុត្រារបស់ព្រះបាទជ័យវរ្ម័នទី២(៨០២-៨៥០)
- ព្រះបាទយសោវរ្ម័នទី១ (៨៨៩-៩០០)
- ព្រះបាទរាជេន្ទ្រវរ្ម័នទី២ (៩៤៤-៩៦៨)
- ព្រះបាទសូរ្យវរ្ម័នទី១ (១០០២ -១០៥០)
- ព្រះបាទទ័យទិត្យវរ្ម័នទី១ (១០៥៦-១០៦០)
- ព្រះបាទហស់វរ្ម័នទី២ (១០៦០-១០៨០)
- ព្រះបាទជ័យវរ្ម័នទី៦ (១០៨០-១១០៩)
- ព្រះបាទសូរ្យវរ្ម័នទី២ (១១១៣-១១៥០)

ព្រះមហាក្សត្រដែលបានកសាងប្រាសាទព្រះវិហារ និងជួសជុលប្រាសាទ ដែលលេចធ្លោមានដូចជា៖

- ព្រះបាទយសោវរ្ម័នទី១៖ ព្រះអង្គបានសាងសង់ប្រាសាទកណ្តាល។
- ព្រះបាទសូរ្យវរ្ម័នទី១៖ ព្រះអង្គបានសាងសង់អគារដ៏វែងនៅជិតប្រាង្គកណ្តាល កំពែងព័ទ្ធជុំវិញ និងគោបុរៈទី៣។ យោងតាមសិលាចារឹករបស់ប្រាសាទ ព្រះបាទសូរ្យវរ្ម័នទី១ បានរៀបចំពិធីដើម្បីអញ្ជើញទេវៈ កទ្រស្វរៈ ដែលគង់នៅវត្តភូ (ប្រទេសឡាវ) មកគង់នៅជាមួយនិងទេវៈ ស្រីសិខរិស្វរៈ ដើម្បីជួយការពារ និងថែរក្សាអាណាចក្រខ្មែរ និងប្រជារាស្ត្រ។
- ព្រះបាទជ័យវរ្ម័នទី៦៖ ព្រះអង្គបានសាងសង់ហោត្រៃ ឬបណ្ណាល័យពីរ និងជួសជុលផ្នែកមួយចំនួននៃប្រាសាទ។
- ព្រះបាទសូរ្យវរ្ម័នទី២៖ ព្រអង្គបានសាងសង់ព្រះលាន ដែលមាននាគក្បាលប្រាំពីរ រូបតោតាមផ្លូវ និងនាគជាច្រើនទៀតតាមជណ្តើរឡើង។ ព្រះអង្គបានរៀបចំពិធីសម្ពោធប្រាសាទ និងចាត់ទុកជាកន្លែងគោរពសម្រាប់ព្រះមហាក្សត្រគ្រប់រូប។

តាមការស្រាវជ្រាវពីឯកសារប្រវត្តិសាស្ត្រខ្មែរជាច្រើន បានឱ្យដឹងថា ប្រាសាទព្រះវិហារត្រូវបានស្ថាបនាឡើងពីថ្មភក់ ចាប់តាំងពីរជ្ជកាល ព្រះបាទសូរ្យវរ្ម័នទី១ ។ ព្រះបាទសូរ្យវរ្ម័នទី១ សោយរាជ្យ នៅពាក់កណ្តាលទីមួយនៃសតវត្សទី១១។ ទីតាំងធ្វើប្រាសាទ ដែលស្ថិតនៅលើទីខ្ពស់ជាងគេ នោះមានកំពស់ ៦២៥ម៉ែត្រ (ឯកសារបារាំង) ឬ៦១៥ម៉ែត្រ (ឯកសារអង់គ្លេស) ។ ប្រវត្តិនៃការកសាងប្រាសាទព្រះវិហារ មាននៅលើសិលាចារឹកខ្មែរនៅប្រាសាទបាពួន ក្នុងខេត្តសៀមរាប គឺK-៥៨៣ ៖ អ្នកដែលចារសិលាចារឹកគឺមានឈ្មោះ ហរិវាហៈ នៅក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័នទី១ ឆ្នាំ៩៤៤ ដល់ ឆ្នាំ៩៦៨ នៃគ.ស ។ បានចារជាភាសាសំស្ក្រឹត និងជាភាសាខ្មែរបុរាណ ។ បានចារថា មានព្រះអង្គម្ចាស់មួយអង្គព្រះនាម ឥន្ទ្រាយុទ្ធ លោកបានយកលិង្គមួយ ឈ្មោះ ស្រីសិខរិស្វរៈ មកតាំងនៅ និងមកប្រតិស្ឋនៅទីនេះ គឺប្រាសាទព្រះវិហារនេះ។ ព្រះអង្គលោកខ្លាំងពូកែខ្លាំងណាស់ ។ លោកមានមហិទ្ធិឫទ្ធិទៅច្បាំងជាមួយនឹងស្តេចចាម ហើយចាប់ស្តេចចាមនោះបានទៀត ។ ចំពោះសេចក្តីសិលាចារឹកនេះ អ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រគិតថា មិនមានសិលាចារឹកឯណាទៀត និយាយពីចម្បាំងទៅចាប់ស្តេចចាមនោះទេ ក៏ប៉ុន្តែស្តេចដែលលោកចាប់បាននោះ ប្រហែលជាមិនមែនជាស្តេចចាម ដែលត្រួតប្រទេសចាមទាំងមូលនោះទេ ។ ប្រហែលជាស្តេចអង្គតូចមួយ ដែលត្រួតនៅនគរមួយ ដែលមានព្រំប្រទល់នៅជាប់នឹងប្រទេសខ្មែរ។ ប្រាសាទព្រះវិហារ ត្រូវបានបារាំងប្រគល់ទៅឱ្យប្រទេសថៃកាន់កាប់នៅឆ្នាំ១៩៥៤ ហើយត្រូវបានប្រគល់ឱ្យព្រះរាជាណាចក្រកម្ពុជាវិញតាមសាលក្រមចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ នៅតុលាការអន្តរជាតិនៅ ទីក្រុងឡាអេប្រទេសហូឡង់។

# 4. ខេត្ត កោះកុង

## 1.1 កោះស្ដេច រីសត




កោះស្ដេច រីសត ឬក៏គេច្រើនហៅថា កោះស្ដេច រីសត ឆ្នេរដូង មានទីតាំងស្ថិតនៅភូមិកោះស្ដេច ឃុំកោះស្ដេច ស្រុកគីរីសាគរ ខេត្តកោះកុង។ កោះស្ដេចរីសតស្ថិតនៅក្នុងប្រភេទ៖ កោះ, ឆ្នេរសមុទ្យ, កន្លែងស្នាក់នៅ។ រីឯចំណុចសំខាន់ៗនៅ កោះស្ដេច រីសត មានដូចជា៖ កន្លែងគេង, ទស្សនាទេសភាពព្រៃភ្នំ, លេងទឹក ឬហែលទឹក, ឆ្នេរសមុទ្រ, ដើរលេងដោយថ្មើរជើង, ជិះទូក, ស្ទូចត្រី, គយគន់ថ្ងៃលិច, គយគន់ថ្ងៃរះ និងចំណុចផ្សេងៗទៀត។



## 1.2 ទឹកធ្លាក់ ស្ទឹងពង្រួល

ទឹកធ្លាក់ ស្ទឹងពង្រួល មានទីតាំងស្ថិតនៅឃុំដងពែក ស្រុកស្រែអំបិល ខេត្តកោះកុង និងមានចម្ងាយប្រហែល ~154km ពីរង្វង់មូលខេត្តកោះកុង។
ទឹកធ្លាក់ ស្ទឹងពង្រួល ស្ថិតនៅក្នុងប្រភេទ៖ ទឹកជ្រោះឬទឹកធ្លាក់, ព្រៃភ្នំ។ រីឯចំណុចសំខាន់ៗនៅ ទឹកធ្លាក់ ស្ទឹងពង្រួល មានដូចជា៖ លេងទឹកឬហែលទឹក, រៀបចំអាហារដោយខ្លួនឯង, ឡើងភ្នំ, ដើរលេងដោយថ្មើរជើង និងចំណុចផ្សេងៗទៀត។ផ្ទាំងថ្មធំៗពូនជាប្រាំងចោទកម្ពស់ជាង ១០ ម៉ែត្រ ច្រៀករហែកស្នាមប្រេះឲ្យទឹកហូរវិញៗពីដងស្ទឹងពង្រួលតាមក្រហែងទម្លាក់ខ្លួនបែកផ្សេងត្រជាក់ស្រេង។ពីដងស្ទឹងពង្រួល ដែលត្រូវបានទប់ជាទំនប់សម្រាប់កសាងវារីអគ្គិសនីគិរីរម្យទី ៣ សិលាធំសម្បើម ប្រវែងមុខកាត់ប្រមាណជាង ៣០ ម៉ែត្រដែលហាក់កំពុងរង់ចាំប្រកពទឹកហូរពីខាងលើ បែរជាទទួលស្វាគមន៍ទឹកហូរវិញៗសេសសល់

ពីដងស្ទឹងបន្តិចបន្តួចៗទិដ្ឋភាពផ្ទាំងថ្មច្រៀកទឹកឈរលើព្រៃព្រឹក្សានេះបង្កើតបានជាទស្សនីយភាពដ៏ល្អឯកសម្រាប់ឱកាសជួបជុំអង្គុយលេង ងូតទឹកថ្មកដ៏ត្រជាក់ និងថតរូបបញ្ចោតដ៏ស្រៀវឆ្អឹងខ្នងៗទឹកធ្លាក់ស្ទឹងពង្រូលស្ថិតក្នុងតំបន់អភិរក្សរបស់សហគមន៍ប្រជាពលរដ្ឋ ដែលត្រូវបានបង្កើតឡើងដើម្បីអភិរក្សព្រៃឈើ និងសម្បត្តិ





## 1.1 កោះស្ដេច រីសត



ស្ទឹងពពក ឬក៏គេច្រើនហៅថា រិយាខេមស្ទឹងពពក មានទីតាំងស្ថិតនៅភូមិព្រះអង្គកែវ ឃុំដងពែក ស្រុកស្រែអំបិល ខេត្តកោះកុង និងមានចម្ងាយប្រហែល ~155km ពីរង្វង់មូល ខេត្តកោះកុង។



ស្ទឹងពពក ស្ថិតនៅក្នុងប្រភេទ៖ ទឹកជ្រោះឬទឹកធ្លាក់, ព្រៃភ្នំ, កន្លែងស្នាក់នៅ, ទេសចរណ៍ធម្មជាតិ។ រីឯចំណុចសំខាន់ៗនៅ ស្ទឹងពពក មានដូចជា៖ លេងទឹកឬហែលទឹក, រៀបចំអាហារដោយខ្លួនឯង, ឡើងភ្នំ, ដើរលេងដោយថ្មើរជើង, បោះជំរុំ ឬបោះតង់, គយគន់ថ្ងៃលិច, ដើរទស្សនាកសិដ្ឋាន, ម្ហូប, ជិះកង់, ជិះត្រាក់ទ័រសណ្តោងឬរ៉ឺម៉ក, គយគន់ថ្ងៃរះ, ការរៀបចំដំណើរកម្សាន្ត, BBQ, កន្លែងគេង និងចំណុចផ្សេងៗទៀត។






# ៥.ខេត្តរតនគិរី



## 1.1 បឹងយក្ខឡោម

បឹងយក្ខឡោម មានទីតាំងស្ថិតនៅ ឃុំយក្ខឡោម ក្រុងបានលុង ខេត្តរតនគីរី និងមានចម្ងាយប្រហែល ~9km ពីវិមានឯករាជ្យក្រុងបានលុង។
បឹងយក្ខឡោម ស្ថិតនៅក្នុងប្រភេទ៖ បឹងឬស្រះឬអាង, ប្រវត្តិសាស្ត្រ, ទេសចរណ៍ធម្មជាតិ, តំបន់វប្បធម៌ឬប្រពៃណី។ រីឯចំណុចសំខាន់ៗនៅ បឹងយក្ខឡោម មានដូចជា៖ លេងទឹកឬហែលទឹក, លក់វត្ថុអនុស្សាវរីយ៍, ជិះដំរី, ទស្សនាផ្ទះជនជាតិភាគតិច និងចំណុចផ្សេងៗទៀត។

ទិដ្ឋភាពក្នុងបឹងយក្សឡោម មានព្រៃដុះអមជុំវិញ និងមានបឹងមួយយ៉ាងធំ។ ភ្ញៀវទេសចរម្នាក់ៗ នៅពេលដែលទៅដល់បឹងនេះភ្លាម ពួកគេប្រញាប់ប្រញាល់ផ្លាស់ប្តូរសំលៀកបំពាក់ និងទាញម៉ាស៊ីនថតដើម្បីទៅហែលទឹក និងថតរូបទុកជាអនុស្សាវរីយ៍។ ភ្ញៀវទេសចរគ្រប់ៗគ្នា ដែលទៅទស្សនានៅបឹងយក្សឡោមបានសរសើរមិនដាច់ពីមាត់ឡើយថាបឹងនេះមានទេសភាពស្អាត ទឹកបឹងមានពណ៌ខៀវស្រងាត់ ដែលធ្វើឲ្យអ្នកដែលបានទៅកម្សាន្តនៅទីនោះមិនចង់ត្រឡប់មកវិញឡើយ។



## 1.2 ទឹកជ្រោះ កាទៀង

ទឹកជ្រោះកាទៀង ឬក៏គេច្រើនហៅថា ទឹកធ្លាក់ កាទៀង មានទីតាំងស្ថិតនៅ ភូមិកាទៀង ឃុំល្បាង២ ស្រុកលំផាត់ ខេត្តរតនគីរី និងមានចម្ងាយប្រហែល ~17km ពីវិមានឯករាជ្យក្រុងបានលុង។ ទឹកជ្រោះកាទៀង ស្ថិតនៅក្នុងប្រភេទៈ ទឹកជ្រោះឬទឹកធ្លាក់, ទេសចរណ៍ធម្មជាតិ។ រីឯចំណុចសំខាន់ៗនៅ ទឹកជ្រោះកាទៀង មានដូចជាៈ លេងទឹកឬហែលទឹក, ទស្សនាទេសភាពព្រៃភ្នំ, ដើរឆ្លងស្ពានយោល, ជិះដំរី, ម្ហូប, រៀបចំអាហារដោយខ្លួនឯង និងចំណុចផ្សេងៗទៀត។

គេហៅឈ្មោះទឹកធ្លាក់នេះ តាមជនជាតិគ្រឹងនៅភូមិកាទៀង។ ទឹកធ្លាក់កាទៀង ស្ថិតនៅក្រោមខ្សែទឹកធ្លាក់កាចាញប្រមាណ ៣គ.ម។ ទឹកធ្លាក់នេះមានកំពស់ប្រមាណ ១០ម ផ្នែកខាងលើមានសណ្ឋានជាផ្ទាំងថ្មរាបស្មើ ដែលទឹកហូរ កាត់ធ្លាក់ទៅក្នុងជ្រោះខាងក្រោម យើងមិនអាចចុះជ្រោះខាងក្រោមបានទេ ព្រោះច្រាំងជ្រោះទាំងសងខាងចោទពេក។ នៅជុំវិញទឹកធ្លាក់មានព្រៃឈើតូចធំដែផ្តល់ម្លប់ត្រឈឹងត្រឈៃគួរឲ្យចង់សម្រាកអង្គុយមើលទឹកធ្លាក់ ឬក៏បរិភោគអាហារពិកនិកនៅទីនោះដោយក្តីរីករាយ។





## 1.3 ឧទ្យានជាតិវីរៈជ័យ

ឧទ្យានជាតិវីរៈជ័យ មានទីតាំងស្ថិតនៅ ក្រុងបានលុង ខេត្តរតនគីរី និងមានចម្ងាយប្រហែល ~101km ពីវិមានឯករាជ្យក្រុងបានលុង។ ឧទ្យានជាតិវីរៈជ័យ ស្ថិតនៅក្នុងប្រភេទៈ ឧទ្យានជាតិ, ព្រៃភ្នំ។ រីឯចំណុចសំខាន់ៗនៅ ឧទ្យានជាតិវីរៈជ័យ មានដូចជាៈ ទស្សនាទេសភាពព្រៃភ្នំ, គយគន់ថ្ងៃលិច, មើលសត្វ និងចំណុចផ្សេងៗទៀត។

ឧទ្យានជាតិវីរៈជ័យ គឺជាកន្លែងលំហែអារម្មណ៍បំបាត់ក្តីទុក្ខ និងស្រូបយកខ្យល់អាកាសដ៏ល្អបរិសុទ្ធមួយមិនគួរមើលរំលង។ ធម្មជាតិបានបង្កើតផ្ទាំងទស្សនីយភាពជាច្រើន ក្នុងឧទ្យានមួយនេះសឹងមិនជឿហើយមានទាំងដើមឈើចម្រុះពណ៌យ៉ាងស្រស់បំព្រង។ នៅទីនោះសត្វព្រៃជាច្រើនកំពុងសំងំរស់នៅយ៉ាងមានសេចក្តីសុខដូចជា សត្វស្វា, ជ្រូកព្រៃ, ខ្លា, ខ្លាឃ្មុំ និងមានសត្វផ្សេងៗទៀត។

ឧទ្យានជាតិវីរៈជ័យ លាតសន្ធឹងលើផ្ទៃដីរាប់រយហិកតា គ្របដណ្តប់ដោយវាលស្មៅដ៏ខៀវខ្ចី នៅលើកំពូលភ្នំដ៏ស្រស់ស្អាត។

បើយើងនិយាយពីសក្តានុពលក្នុងឧទ្យានជាតិវីរៈជ័យនេះវិញ យើងសង្កាត់ឃើញថាមានធម្មជាតិក្នុងព្រៃ មានដងអូរ និងរួមទាំងសត្វព្រៃដែលជាអ្វីដែលធ្វើឲ្យឧទ្យានជាតិមួយនេះមានសម្រស់ស្រស់ត្រកាលបង្អួតដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលបានទៅដល់ទីនោះ។





# 6. ខេត្ត មណ្ឌលគិរី




## 1.1 រមណីយដ្ឋាន ដំណាក់ស្ដេច

ដំណាក់ស្ដេច មានទីតាំងស្ថិតនៅភូមិដើមស្រល់សង្កាត់មនោរម្យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី និងមានចម្ងាយប្រហែល ~9km ពីរង្វង់មូលគោព្រៃ។

ដំណាក់ស្ដេច ស្ថិតនៅក្នុងប្រភេទ៖ ទឹកជ្រោះឬទឹកធ្លាក់, ទេសចរណ៍ធម្មជាតិ។ រីឯចំណុច សំខាន់ៗនៅដំណាក់ស្ដេច មានដូចជា៖ ទស្សនាទេសភាពព្រៃភ្នំ, លេងទឹកឬហែលទឹក, គយគន់ថ្ងៃលិច, គយគន់ថ្ងៃរះ និងចំណុចផ្សេងៗទៀត។



## 1.2 ភ្នំដោះក្រមុំ

ភ្នំដោះក្រមុំ មានទីតាំងស្ថិតនៅ សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី និងមានចម្ងាយប្រហែល ~2km ពីរង្វង់មូលគោព្រៃ។
ភ្នំដោះក្រមុំ ស្ថិតនៅក្នុងប្រភេទ៖ ព្រៃភ្នំ។ រីឯចំណុចសំខាន់ៗនៅ ភ្នំដោះក្រមុំ មានដូចជា៖ ទស្សនាទេសភាពព្រៃភ្នំ, គយគន់ថ្ងៃលិច, គយគន់ថ្ងៃរះ និងចំណុចផ្សេងៗទៀ

## 1.3 សួនសត្វ អូទ្រីស



សួនសត្វ អូទ្រីស មានទីតាំងស្ថិតនៅ ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី និងមានចម្ងាយប្រហែល ~20km ពីរង្វង់មូលគោព្រៃ។
សួនសត្វ អូទ្រីស ស្ថិតនៅក្នុងប្រភេទ៖ សួនសត្វ។ រីឯចំណុចសំខាន់ៗនៅ សួនសត្វ អូទ្រីស មានដូចជា៖ ទស្សនាទេសភាពព្រៃភ្នំ, ដើរទស្សនាកសិដ្ឋាន, គយគន់ថ្ងៃលិច, ដើរលេងដោយថ្មើរជើង, មើលសត្វអូទ្រីស និងចំណុចផ្សេងៗទៀត។
សត្វអូទ្រីសទាំងនេះមានប្រមាណជាង២០ក្បាល ដែលកំពុងត្រូវមើលថែទាំយ៉ាងយកចិត្តទុកដាក់ពីអ្នកមើលថែ និងធ្វើជារបងហ៊ុំព័ទ្ធបរិវេណនៅតំបន់ខ្ពង់រាបចង្កេះភ្នំសម្រាប់ឱ្យសត្វអូទ្រីសទាំងនេះរត់ ដើរ ដោយសេរីភាព។

## 1.4 ទឹកជ្រោះ ប៊ូស្រា

ទឹកជ្រោះ ប៊ូស្រា ស្ថិតនៅក្នុងប្រភេទ៖ ទឹកជ្រោះឬទឹកធ្លាក់, ទេសចរណ៍ធម្មជាតិ។ រីឯចំណុចសំខាន់ៗនៅ ទឹកជ្រោះ ប៊ូស្រា មានដូចជា៖ លេងទឹកឬហែលទឹក, ជិះខ្សែរ៉ក, ម្ហូប, រៀបចំអាហារដោយខ្លួនឯង, ដើរលេងដោយថ្មើរជើង និងចំណុចផ្សេងៗទៀត។
ទឹកជ្រោះនេះជាតំបន់ទេសចរណ៍ល្អជាងគេក្នុងខេត្តមណ្ឌលគិរី។ ទឹកជ្រោះដ៏ទាក់ទាញនេះត្រូវបានចែកចេញជាបីដំណាក់។ ដំណាក់ទី១ ហូរធ្លាក់ក្នុងកម្ពស់៨ទៅ ១២ម៉ែត្រ ដែលមានមុខកាត់ទទឹង១៥ម៉ែត្រ នៅរដូវវស្សា និងកម្ពស់ពី១០ទៅ១៥ម៉ែត្រ នៅរដូវប្រាំង។ ដំណាក់ទី២ ហូរធ្លាក់ពីកម្ពស់១៥ ទៅ២០ម៉ែត្រ និងមានមុខកាត់ទទឹង២០ម៉ែត្រ នៅរដូវវស្សា និងកម្ពស់ពី១៨ ទៅ២៥ម៉ែត្រ ដែលមានមុខកាត់ ១៣ម៉ែត្រ នៅរដូវប្រាំង ទឹកធ្លាក់ទី២នេះ មានចម្ងាយ១៥០ម៉ែត្រពីទឹកធ្លាក់ទី១។ ដំណាក់ទី៣ ហូរធ្លាក់ដោយល្បឿនលឿនខ្លាំងជាងល្បាក់ទី២។ ល្បាក់នេះ យើងមិនអាចទៅដល់បានទេ ពីព្រោះជាតំបន់ព្រៃក្រាស់ ខ្វះមធ្យោបាយធ្វើដំណើរ និងជាតំបន់គ្រោះថ្នាក់ដោយសារពពួកសត្វព្រៃ។
ក្រៅពីផ្ងូតទឹកជ្រោះធម្មជាតិដ៏ត្រជាក់ដល់ក្រអៅបេះដូងនិងអង្គុយទទួលទានអាហារដ៏មានឱជារសជាមួយមិត្តភក្តិ និងក្រុមគ្រួសារ ក្រោមដំនោរចំហាយទឹកជ្រោះដ៏ត្រជាក់នោះ ភ្ញៀវទេសចរទាំងអស់ក៏អាចចំណាយពេលតុបតែង និងស្លៀកពាក់បែបជនជាតិដើមភាគតិចព្នងដើម្បីថតរូបទុកជាអនុស្សាវរីយ៍ផងដែរ។

សម្រាប់ខេត្តមណ្ឌលគិរី ទឹកជ្រោះប៊ូស្រា នៅតែជាទីដ៏ទាក់ទាញបំផុត ដែលគ្រប់ភ្ញៀវទាំងអស់នៅពេលមកដល់ខេត្តនេះមិនអាចមើលរំលងបាន។











# 7. ខេត្ត ក្រចេះ

## 1.1 កោះផ្ដៅ



*កោះផ្ដៅឬក៏គេច្រើនហៅថាសហគមន៍អេកូ-ទេសចរណ៍កោះផ្ដៅ, សហគមន៍ទេសចរណ៍ កោះផ្ដៅ មានទីតាំងស្ថិតនៅ ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ និងមានចម្ងាយប្រហែល* ~45km *ពីរង្វង់មូលក្រុងក្រចេះ។*

*កោះផ្ដៅ ស្ថិតនៅក្នុងប្រភេទ៖ ទេសចរណ៍ធម្មជាតិ, កោះ, ឆ្នេរសមុទ្យ។*

*រីឯចំណុចសំខាន់ៗនៅ កោះផ្ដៅ មានដូចជា៖ ជិះកង់, ជិះទូក, ឆ្នេរសមុទ្រ, បោះជំរុំឬបោះតង់, ស្ទូចត្រី, ជិះទូកកាយ៉ាក, រៀបចំអាហារដោយខ្លួនឯង, លេងទឹកឬហែលទឹក, ដើរលេងដោយថ្មើរជើង និងចំណុចផ្សេងៗទៀត។ សហគមន៍អេកូ-ទេសចរណ៍កោះផ្ដៅ ចម្ងាយ ៤៥គ.ម ពីខេត្តក្រចេះ កោះផ្ដៅ និងសំភិន គឺជាភូមិពីរក្នុងចំណោមភូមិដ៏ទៃទៀតដែលស្ថិតនៅលើកោះរងាវ។ កោះរងាវ ជាកោះមួយដែលវែងជាងគេបំផុតក្នុងចំណោមកោះដ៏ទៃទៀត មានប្រវែង ៤៥គីឡូម៉ែត្រ ស្ថិតនៅតាមបណ្ដោយដងទន្លេមេគង្គក្នុងប្រទេសកម្ពុជា។ ភូមិទាំងពីរនេះស្ថិតនៅក្នុងឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ តាមបណ្ដោយដងទន្លេមេគង្គភាគខាងជើងចម្ងាយប្រមាណ ៤៤គីឡូម៉ែត្រ ពីរួមខេត្តក្រចេះ។ ដើម្បីទៅដល់ភូមិនេះអ្នកធ្វើដំណើរត្រូវធ្វើដំណើរតាមផ្លូវគោកប្រវែងប្រមាណ ៣៨គីឡូម៉ែត ពីទីរួមខេត្តក្រចេះទៅកាន់ស្រុកសំបូរ និងបន្តដំណើរតាមទូកពីស្រុកសំបូរទៅភូមិទាំងពីរខាងលើចម្ងាយ ៦គីឡូម៉ែតទៀត។*

## 1.2 អន្លង់ផ្សោត



*អន្លង់ផ្សោត ឬក៏គេច្រើនហៅថា អន្លង់ផ្សោតកាំពី, កាំពី មានទីតាំងស្ថិតនៅ ភូមិព្រែកកាំពី ឃុំសំបុក ស្រុកចិត្របុរី ខេត្តក្រចេះ និងមានចម្ងាយប្រហែល* ~16km *ពីរង្វង់មូលក្រុងក្រចេះ។*

*អន្លង់ផ្សោត ស្ថិតនៅក្នុងប្រភេទ៖ ភោជនីយដ្ឋាន, ទេសចរណ៍ធម្មជាតិ។*

*រីឯចំណុចសំខាន់ៗនៅ អន្លង់ផ្សោត មានដូចជា៖ ម្ហូប, លេងទឹកឬហែលទឹក, ជិះទូក, ស្ទូចត្រី, ដើរមើលសត្វផ្សោត និងចំណុចផ្សេងៗទៀត។*

*រមណីយដ្ឋានអន្លង់ផ្សោត ជាតំបន់ទេសចរណ៍បែបធម្មជាតិដ៏ទាក់ទាញមួយក្នុងចំណោមតំបន់ទេសចរណ៍ជាច្រើនទៀតនៅក្នុងខេត្តក្រចេះ ហើយទីនោះក៏ជាទីតាំងកម្សាន្តទាក់ទាញមួយសម្រាប់ភ្ញៀវទេសចរដែលចង់ផ្លូតទឹកកំសាន្ត ញុំាអាហារបែបស្រុកស្រែ ឬ សំរាកថ្ងៃចុងសប្តាហ៍ ជាមួយនឹងក្រុមគ្រួសារ ឬ មិត្តរួមការងារ ឬ មិត្តភក្តិជាដើម។*

*រមណីយដ្ឋានអន្លង់ផ្សោតត្រូវបានសហគមន៍ក្នុងតំបន់នោះរៀបចំយ៉ាងស្អាត ដោយមានកញ្ចុះសំរាប់អង្គុយលេង និងមានអង្រឹងសម្រាប់គេងផងដែរ។*

*លើសពីនេះ ទីនោះក៏មានទូកម៉ាស៊ីន សម្រាប់ដឹកភ្ញៀវទេសចរតាមទន្លេមេគង្គ ដើម្បីទស្សនាផ្សោត។ ចំពោះពេលវេលាដែលល្អបំផុតក្នុងការទស្សនាផ្សោត គឺក្នុងរដូវប្រាំង នាពេលព្រឹកព្រលឹម និងពេលល្ងាច។ ទោះបីជាផ្សោតមានផ្លាស់ប្តូរជម្រកពីកន្លែងមួយទៅកន្លែងមួយទៀតតាមរដូវក៏ដោយ ប៉ុន្តែអ្នកបើកទូកម៉ាស៊ីនបានដឹងយ៉ាងច្បាស់ថាពួកវាប្តូរទៅរស់នៅទីណាខ្លះ។*

*នៅរមណីយដ្ឋានអន្លង់ផ្សោត ឬ កាំពី ក៏មានចំណីអាហារ គេសជ្ជៈ ហើយមានវត្ថុអនុស្សាវរីយ៍ដូចជា៖ រូបភាព, ចម្លាក់ផ្សោតធ្វើអំពីឈើជាដើម ដែលបានផលិត និងដាក់លក់ដោយសហគមន៍នៅក្នុងតំបន់នោះ។*

## 1.3 ភ្នំសំបុក



*ភ្នំសំបុក ឬក៏គេច្រើនហៅថា វត្តភ្នំសំបុក, រមណីយដ្ឋាន ភ្នំសំបុក, បូជនីយដ្ឋាន ភ្នំសំបុក, ភ្នំសំបូរមាស មានទីតាំងស្ថិតនៅ ភូមិថ្មក្រែ ឃុំថ្មក្រែ ស្រុកចិត្របុរី ខេត្តក្រចេះ និងមានចម្ងាយប្រហែល ~9km ពីរង្វង់មូលក្រុងក្រចេះ។*

*ភ្នំសំបុក ស្ថិតនៅក្នុងប្រភេទ៖ សញ្ញាសំគាល់, ព្រៃភ្នំ, ប្រវត្តិសាស្ត្រ។ រីឯចំណុចសំខាន់ៗនៅ ភ្នំសំបុក មានដូចជា៖ រៀបចំអាហារដោយខ្លួនឯង, ទស្សនាទេសភាពព្រៃភ្នំ, ទស្សនាវត្ត និងចំណុចផ្សេងៗទៀត។*

*ភ្នំសំបុកបានក្លាយជាទីវត្តអារាម ដែលមានកេរ្តិ៍ឈ្មោះល្បីតាំងពីដើមសតវត្សរ៍ទី ១៩ ហើយមានមនុស្សជាច្រើនទៅគោរព បន់ស្រន់តាមជំនឿរបស់ខ្លួន។ ភ្នំនេះមានកម្ពស់ ៧០ ម៉ែត្រ និងចម្ងាយប្រហែល ៣០០ ម៉ែត្រពីផ្លូវធំ ហើយមានជណ្តើរសំរាប់ឡើងទៅកាន់អារាមខាងលើ។ កាលពីដើមឡើយ ភ្នំនេះមានឈ្មោះដំបូងថា "ភ្នំសំបូរមាស" ដោយតាមរឿងព្រេងនិទាន ទើបធ្វើអោយភ្នំនេះនៅសល់ឈ្មោះត្រឹម "ភ្នំសំបុក"។*

*ភ្នំនេះមានទស្សនីយភាពដ៏ល្អត្រកាល និងមានលក្ខណៈអំណោយផលទាំងភូមិសាស្ត្រ និងសុវត្ថិភាព ដល់ភ្ញៀវទេសចរ។ ភ្នំនេះត្រូវបានគេរៀបចំឲ្យក្លាយទៅជារមណីយដ្ឋានទេសចរតាំងពីសម័យសង្គមរាស្ត្រនិយមមកម៉្លេះ។ នៅជាប់ជើងភ្នំប៉ែកខាងលិចមានបឹងដ៏ធំមួយ ដែលមានទឹកថ្លាឆ្វេង និងមានធម្មជាតិដុះឡើងស្រស់បំព្រង។*

*រីឯកំពូលភ្នំសំបុកមានលក្ខណៈព្រែកជាពីរ មួយទាបមួយខ្ពស់ ពេលឡើងដល់កំពូលភ្នំ គេអាចមើលឃើញនូវទិដ្ឋភាពដ៏ស្រស់ត្រកាល ពិសេសដងទន្លេមេគង្គ។ ចំណែកឯ តួភ្នំសំបុកវិញ មានដើមឈើធំៗដុះស្អេកស្កាស់ និងមាន*



សត្វបក្សាបក្សីស្រែកឆ្លើយឆ្លងគ្នាឥតដាច់។ បើនិយាយអំពីការធ្វើដំណើរឡើងទៅវិញ ពីជើងភ្នំរហូតដល់កំពូលភ្នំ មានជណ្ដើរធ្វើពីបេតុងសំរាប់ធ្វើដំណើរឡើងចុះយ៉ាងងាយស្រួល និងមានដំណាក់សំរាកលំហែរកាយជាច្រើនកន្លែងថែមទៀតផង។





# 8. ខេត្ត ពោធិ៍សាត់

## 1.1 ភ្នំ១៥០០



ភ្នំ១៥០០ មានទីតាំងស្ថិតនៅ ស្រុកវាលវែង ខេត្តពោធិ៍សាត់ និងមានចម្ងាយប្រហែល~150km ពីកោះសំពៅមាស។

ភ្នំ១៥០០ ស្ថិតនៅក្នុងប្រភេទ៖ ព្រៃភ្នំ, ទេសចរណ៍ធម្មជាតិ។ រីឯចំណុចសំខាន់ៗនៅ ភ្នំ១៥០០ មានដូចជា៖ ទស្សនាទេសភាពព្រៃភ្នំ, គយគន់ថ្ងៃលិច, គយគន់ថ្ងៃរះ, រៀបចំអាហារដោយខ្លួនឯង, ដើរលេងដោយថ្មើរជើង និងចំណុចផ្សេងៗទៀត។

## 1.2 ទឹកធ្លាក់ ថ្មដាតូច

ទឹកធ្លាក់ ថ្មដាតូច ឬក៏គេច្រើនហៅថា ទឹកធ្លាក់ ភ្នំ ១០០៥ មានទីតាំងស្ថិតនៅ ភូមិឯកភាព ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ និងមានចម្ងាយប្រហែល ~170km ពីកោះសំពៅមាស។

ទឹកធ្លាក់ ថ្មដាតូច ស្ថិតនៅក្នុងប្រភេទ៖ ទឹកជ្រោះឬទឹកធ្លាក់, ទេសចរណ៍ធម្មជាតិ។ រីឯចំណុចសំខាន់ៗនៅ ទឹកធ្លាក់ ថ្មដាតូច មានដូចជា៖ រៀបចំអាហារដោយខ្លួនឯង, លេងទឹកឬហែលទឹក, ទស្សនាទេសភាពព្រៃភ្នំ និងចំណុចផ្សេងៗទៀត។

បើយើងធ្វើដំណើរទៅកាន់តំបន់នោះ យើងប្រាកដជាបានធ្វើដំណើរលើវិថីពត់ពែន តាមជម្រាលភ្នំខ្ពស់ៗប្រាកដជាធ្វើឲ្យភ្ញៀវទេសចរទទួលបាននូវបទពិសោធន៍ថ្មីៗ។ សូមបញ្ជាក់ទីនោះ មិនទាន់មានការលើកស្លាកសញ្ញាសម្គាល់ជាតម្រុយឲ្យងាយស្រួលដល់ភ្ញៀវទេសចរក្នុងការធ្វើដំណើរនៅឡើយទេ។ ដូចច្នេះហើយភ្ញៀវទេសចរដែលប្រាថ្នាទៅលេង ចាំបាច់ត្រូវសួរអ្នកភូមិតាមផ្លូវដើម្បីកុំឲ្យវង្វេងផ្លូវ។

ភ្ញៀវទេសចរនឹងបានឃើញ ទឹកហូរលើជម្រាលថ្មជាដំណាក់ៗ ដូចជាកាំជណ្តើរ ដែលផ្តល់ភាពងាយស្រួលក្នុងការងូតទឹកកម្សាន្តដល់ភ្ញៀវទេសចរ ជាមួយនឹងទេសភាពព្រៃព្រឹក្សាដែលកម្ររកបាន។ នៅពេលដែលភ្ញៀវទេសចរបានទៅដល់ទីនោះ ភ្ញៀវទេសចរនឹងបានឃើញទឹកហូររឹមៗ លើកម្រាលថ្មរាបស្មើ និងពេលដើរចុះទៅតាមខ្សែទឹកធ្លាក់ខាងក្រោមដែលកំពុងហូរជាថ្នាក់ៗនោះ ភ្ញៀវទេសចរនឹងទទួលបាននូវអារម្មណ៍ស្រស់ស្រាយជាក់ជាមិនខានឡើយ។ ក្រៅពីការងូតទឹកដ៏សែនត្រជាក់ នៅមានការគយគន់ព្រៃព្រឹក្សា ឮសូរសំឡេងសត្វព្រៃយំខ្សៀវខ្សារថែមទៀតផង។

ទឹកធ្លាក់ថ្មដាតូចនេះមាន ២ដំណាក់ ដែលដំណាក់ខាងលើជាទីឋានសម្រាប់ ងូតទឹកលេងកម្សាន្តដោយសារដំណាក់ នេះ មានទឹកធ្លាក់ហូរលើជម្រាលជា ថ្នាក់ៗ ដូចកាំជណ្ដើរៗ រីឯ ដំណាក់ ខាងក្រោមវិញ វាជាល្បាក់ទឹកធ្លាក់ ដែលកម្ពស់ប្រហែលជាជិត ១០ម៉ែត្រ សម្រាប់ឲ្យភ្ញៀវទេសចរណាដែលចង់ ហែលទឹកលេងកម្សាន្ត។



## 1.3 វត្តភ្នំបាក់ត្រា

វត្តភ្នំបាក់ត្រា មានទីតាំងស្ថិតនៅ ភូមិអូរបាក់ត្រា ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ និងមានចម្ងាយ ប្រហែល ~18km ពីកោះសំពៅមាស។
វត្តភ្នំបាក់ត្រា ស្ថិតនៅក្នុងប្រភេទ៖ ព្រៃភ្នំ, សញ្ញាសំគាល់ៗ រីឯចំណុចសំខាន់ៗនៅ វត្តភ្នំបាក់ត្រា មានដូចជា៖ រៀបចំអាហារដោយខ្លួនឯង, ទស្សនាវត្ត, ទស្សនាទេសភាពព្រៃភ្នំ, ដើរលេងដោយថ្មើរជើង និងចំណុចផ្សេងៗទៀត។
វត្តភ្នំបាក់ត្រាលើ ល្បីស័ក្តិសិទ្ធិបន់ស្រន់បានដូចបំណងដែលធ្វើឲ្យមនុស្សគ្រប់គ្នា មកបណ្ដាខេត្តជិត ឆ្ងាយ រហូតពលរដ្ឋខ្មែររស់នៅក្រៅប្រទេសមកបន់ស្រន់ក៏មាន។
ក្រៅពីជាទីវត្តអារាម វត្តភ្នំបាក់ត្រា ត្រូវបានគេចាត់ទុកថាជារមណីយដ្ឋានមួយ ហើយជារាល់ថ្ងៃចុងសប្តាហ៍ ឬ ថ្ងៃបុណ្យ រមែងមានពុទ្ធបរិស័ទជិតឆ្ងាយមកធ្វើបុណ្យផង និងកម្សាន្តផង ព្រោះនៅក្នុងបរិវេណវត្តប្រមាណជា ៣គីឡូម៉ែត្រ សំបូរទៅដោយដើមឈើជាច្រើន និងមានថ្មដា តូច ធំ ជាពិសេសនោះមានខ្យល់អាកាសបរិសុទ្ធដែលធ្វើឲ្យភ្ញៀវទេសចរទទួលបានអារម្មណ៍ស្រស់ស្រាយ។



# ១. ខេត្តបាត់ដំបង

ខេត្តបាត់ដំបង គឺជាខេត្តមួយនៅភាគពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា។ ខេត្តបាត់ដំបង មានទីប្រជុំជនធំនៅក្រុងបាត់ដំបង។ ខេត្តបាត់ដំបងមានព្រំប្រទល់ ខាងជើងជាប់ខេត្តបន្ទាយមានជ័យ ខាងកើតជាប់ខេត្តសៀមរាប និងបឹងទន្លេសាប ខាងត្បូងជាប់ខេត្តពោធិ៍សាត់ ខាងលិចជាប់ខេត្តប៉ៃលិន និងខេត្តច័ន្ទបុរី(ប្រទេសថៃ)។



## 1.1 ប្រាសាទភ្នំបាណន់

ប្រាសាទភ្នំបាណន់ស្ថិតនៅក្នុងភូមិបាណន់ ឃុំកន្ទឺរ២ ស្រុកបាណន់ ខេត្តបាត់ដំបង តាមបណ្តោយដងស្ទឹងសង្កែ មានចម្ងាយ២២គ.មខាងត្បូងទីរួមខេត្តបាត់ដំបង។ ប្រាសាទភ្នំបាណន់ជាប្រាសាទភ្នំ ដែលស្ថិតនៅលើកំពូលភ្នំធម្មជាតិមានកំពស់៨១ម៉ែត ចំណុចនិយាមកាមត្រង់ចំណុច ១២០៥៧'០៣" N និង១០៣០០៨'២៣" E (យកតាម Google Earth ) មានកំពែងព័ទ្ធជុំវិញ មានតួសំខាន់មួយបែរមុខទៅរកទិសទាំងបួន មានក្លោងទ្វារបួន និងមានប្រាសាទជ្រុងបួន។ តួប្រាសាទសំខាន់កណ្តាលសង់អំពីថ្មភក់ រីឯកំពែង ក្លោងទ្វារ និងប្រាសាទជ្រុងសង់អំពីថ្មបាយក្រៀមដែលមានក្បាច់តុបតែងលំអំពីថ្មភក់។ ចំណែកថ្មភក់ដែលគេយកមកសាងសង់ប្រាសាទទៀតសោត ក៏ដឹកមកពីតំបន់ផ្សេងៗគ្នាជាច្រើនកន្លែងផងដែរ នេះបើផ្អែកទៅលើគុណភាពថ្មដែលបន្សល់ទុកនាពេលបច្ចុប្បន្ននេះ។ បើពិនិត្យជាទូទៅប្រាសាទភ្នំបាណន់មានជណ្តើរអាចឡើងនិងចុះពីខឿនប្រាសាទមកចំនួន៣ គឺនៅជ្រុងខាងជើង ខាងត្បូង និងខាងកើត ប៉ុន្តែនៅជ្រុងខាងកើតមានជណ្តើរតាំងពីជើងភ្នំរហូតដល់តួប្រាសាទ។ បើយោងទៅលើចម្លាក់នានាដែលមន្ត្រីជំនាញបានប្រទះឃើញនៅលើតួប្រាសាទ និងនៅជុំវិញបរិវេណប្រាសាទភ្នំបាណន់កន្លងមក ឃើញថាប្រាសាទនេះមានក្បាច់រចនាលាយចំរុះគ្នាជាច្រើនរចនាបថ គឺពីសតវត្សទី៩ រហូតដល់ចុងសតវត្សទី១៣នៃគ.ស ប៉ុន្តែក្បាច់រចនានៅសតវត្សទី១៣នៃគ.ស គឺនៅក្នុងរចនាបថបាយ័ន មានច្រើនជាងគេគឺស្ថិតក្នុងរាជ្យព្រះបាទ ជ័យវរ្ម័នទី៧ ព្រះអង្គសោយរាជ្យពីឆ្នាំ១១៨១ ដល់ឆ្នាំ១២១៨នៃគ.ស។ យើងបានរកឃើញសិលាចារឹកមួយ

ផ្ទាំង K202 ចារនៅឆ្នាំ១០៥០នៃគ.ស គឺក្នុងដើមរាជ្យព្រះបាទឧទ័យទិត្យវរ្ម័នទី២ (១០៥០–១០៦៦នៃគ.ស) ដែលឡើងគ្រងរាជ្យបន្តពីព្រះបិតារបស់ព្រះអង្គគឺព្រះបាទសូរ្យវរ្ម័នទី១ (១០០២–១០៥០នៃគ.ស)។ និងមានសិលាចារឹកមួយផ្ទាំងទៀតចារនៅឆ្នាំ១៨៣០នៃព.ស ត្រូវនឹងឆ្នាំ ១២៨៧នៃគ.ស គឺចុងសតវត្សទី១៣នៃគ.សបាននិយាយថាព្រះបាទជ័យចេស្តារាមេសូជាប្រះរាជបុត្ររបស់ព្រះបាទ សុកណាន បានយកទីនេះធ្វើជាទីសំណាក់ធម៌ដូចវត្តអារាមដែរដើម្បីលើកស្ទួយព្រះពុទ្ធសាសនាឲ្យមានលក្ខណៈកាន់តែល្អប្រសើរឡើង។ ប្រាសាទភ្នំបាណន់សព្វថ្ងៃនៅសល់តួសំខាន់កណ្តាល ក្លោងទ្វារប្រចាំទិសទាំង៤ មួយផ្នែកតូចនៃកំពែងខាងកើតនិងនៅសល់ផ្នែកខ្លះនៃប្រាសាទជ្រុងនៃទិសពាយ័ព្យ។ ដោយសារកត្តាអាយុកាល កត្តាធម្មជាតិ និងកត្តាមនុស្ស ប្រាសាទភ្នំបាណន់បានរងការខូចខាត ជាច្រើន ជាពិសេសនៅក្នុងសម័យសង្គ្រាម។ ប្រជាជននៅតែបន្តជឿទៅលើអាទិទេពនៃប្រាសាទភ្នំបាណន់ ដោយពួកគាត់បានធ្វើពិធីបន់ស្រន់សុំសេចក្តីសុខ សុំទឹកភ្លៀងជារៀងរាល់ឆ្នាំ ដើម្បីប្រកបកសិកម្មឲ្យបានផលច្រើនផងនិងផុតពីជំងឺដង្កាត់ទាំងឡាយផងដែរ។ មិនតែប៉ុណ្ណោះប្រជាជនទូទៅ ជិតឆ្ងាយបានមកលេងកំសាន្តនិងបន់ស្រន់សុំសេចក្តីសុខ និងសុំអ្វីៗទៅតាមការប៉ងប្រាថ្នារបស់ខ្លួន។





## 1.2 តំបន់អភិរក្សដងទុង

ដងទុង គឺជាតំបន់មួយដែលសាកសមបំផុតសម្រាប់ទេសចរដែលស្រលាញ់ធម្មជាតិ វាជាតំបន់អភិរក្សសត្វព្រៃដែលមានសត្វព្រៃដ៏កម្រជាច្រើនប្រភេទ។ មិនតែប៉ុណ្ណោះនៅទីនោះក៏មាននូវអគារបុរាណដែលបានបន្សល់ពីសម័យអាណានិគមនិយមផងដែរ។ នៅក្នុងតំបន់នេះមានធម្មជាតិស្រស់ស្អាត ជាមួយនឹងខ្យល់អាកាសបរិសុទ្ធដែលធ្វើឱ្យអ្នកទេសចរមកលេងកម្សាន្តនៅទីនេះមានអារម្មណ៍ស្រស់ស្រាយ។ ដងទុងមានចម្ងាយប្រហែល54គីឡូម៉ែត្រពីទីរួមខេត្តបាត់ដំបង ដោយធ្វើដំណើរតាមផ្លូវលេខ257។






## 1.3 ទឹកធ្លាក់ភ្នំ 53

ខេត្តកំពង់ចាម គឺជាខេត្តនៃប្រទេសកម្ពុជាដែលស្ថិតនៅវាលទំនាបកណ្ដាលនៃទន្លេមេគង្គ។ វាមានព្រំប្រទល់ជាប់នឹងខេត្តកំពង់ឆ្នាំងនៅខាងលិច កំពង់ធំ និង ក្រចេះនៅខាងជើង ត្បូងឃ្មុំនៅខាងកើត និង ព្រៃវែង និង កណ្ដាលនៅខាងត្បូង។ កំពង់ចាមជាផ្លូវការត្រូវបានបែងចែកទៅជាពីរខេត្តនៅថ្ងៃទី ៣១ ធ្នូ ២០១៣ ជារឿងដែលគេមើលឃើញភាគច្រើនថាជារបត់នយោបាយរបស់បក្សកាន់អំណាច។ ផ្ទៃដីទាំងអស់នៅខាងលិចនៃទន្លេមេគង្គនៅតែជាកំពង់ចាមដដែល គ្រាដែលផ្ទៃដីនៅខាងកើតទន្លេបានក្លាយជាខេត្តត្បូងឃ្មុំ។ មុនការបែងចែកនេះ កំពង់ចាមបានលាតសន្ធឹងទៅខាងកើតដល់ព្រំដែនអន្តរជាតិជាមួយវៀតណាម ធ្លាប់ជាខេត្តធំទី១១នៅកម្ពុជា និងមានប្រជាជន ១ ៦៨០ ៦៩៤ នាក់ ដែលបានចាត់ទុកថាជាខេត្តដែលមានប្រជាជនច្រើនបំផុតទីពីរក្នុងប្រទេស។ ទីរួមខេត្ត និង ក្រុងធំបំផុតរបស់ខេត្តនេះគឺក្រុងកំពង់ចាម។ កំពង់ចាមគឺជាស្រុកកំណើតនៃលោកនាយករដ្ឋមន្ត្រីហ៊ុន-សែនបច្ចុប្បន្ន។







# 10. ខេត្ត បន្ទាយមានជ័យ




ខេត្តបន្ទាយមានជ័យ ជាខេត្តមួយនៃព្រះរាជាណាចក្រកម្ពុជាស្ថិតនៅចុងពាយ័ព្យដែលមានសេដ្ឋកិច្ចយ៉ាងសំខាន់មួយរបស់ប្រទេស។ មានព្រំខេត្តជាប់ខេត្តឧត្តរមានជ័យ និង សៀមរាបនៅខាងកើត ខេត្តបាត់ដំបងនៅខាងត្បូង និងមានព្រំដែនរួមអន្តរជាតិជាមួយថៃនៅខាងលិច។ ទីរួមខេត្តនិងទីក្រុងធំបង្អស់គឺសិរីសោភ័ណ។

បន្ទាយមានជ័យគឺជាខេត្តធំបង្អស់ទី១៣ នៃព្រះរាជាណាចក្រកម្ពុជា។ ដោយមានប្រជាជន ៦៧៨,០៣៣ នាក់ វាជាប់លេខជាខេត្តធំទី ១០ ប្រចាំប្រទេស។ ក្រុងប៉ោយប៉ែតនៅប៉ែកខាងលិចនៃខេត្តគឺជាព្រំដែនអន្តរជាតិឆ្លងចូលទៅប្រទេសថៃ។ បន្ទាយមានជ័យគឺជាខេត្តមួយក្នុងចំណោមខេត្តទាំងប្រាំបួនដែលជាប៉ែកភាគនៃដែនជំរកជីវមណ្ឌលទន្លេសាប។

## 1.1 ប្រាសាទបន្ទាយឆ្មារ

ប្រសាទបន្ទាយឆ្មារជារមណីយដ្ឋានទេសចរណ៍បែប វប្បធម៌ និងប្រវត្តិសាស្ត្រ រមណីយដ្ឋាននេះមានទីតាំងស្ថិតនៅក្នុងភូមិបន្ទាយឆ្មារ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ដែលមានចំងាយប្រមាណជា៦០គីឡូម៉ែត្រពីទីរួមខេត្តបន្ទាយមានជ័យ មានសក្តានុពលទេសចរណ៍សំខាន់គឺប្រាសាទបុរាណ។ភ្ញៀវទេសចរអាចទស្សនាប្រាសាទបុរាណ ស្វែងយល់ជីវភាពរស់នៅរបស់អ្នកភូមិ។



## 1.2 រមណីយដ្ឋាន អាងជើងគ្រុស

រមណីយដ្ឋានអាងគ្រុស ជារមណីយដ្ឋានទេសចរណ៍ធម្មជាតិ ដែលបានបង្កើតសម្រស់យ៉ាងស្រស់ស្អាតនៅឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចេញពីឃុំបន្ទាយឆ្មារប្រមាណ ៣៣២៦ ម៉ែត្រលោកអ្នកនឹងបានទៅដល់អាងមួយយ៉ាងធំ គឺអាងជើងគ្រុស ដែលមានទេសភាពស្រស់ស្អាត ខ្យល់អាកាសបរិសុទ្ធ ជាពេលវេលានិងជាទីកន្លែងសម្រាក់សម្រាកលំហែរកាយដ៏ស្រស់ស្រាយអស់ទុក្ខកង្វល់ ហើយយើងក៏អាចអង្គុយមើលថ្ងៃរៀបអស្ដង្គតយ៉ាងស្រស់ស្អាតថែមទៀតផង លើសពីនេះទៅទៀតភ្ញៀវទេសចរក៏អាចជិះកាណូតទៅកម្សាន្តលេងនៅលើកូនកោះកណ្ដាលអាងបានទៀតផងដែរ ដែលយើងបានប្រែក្លាយអាងដែលគ្មានមនុស្សចាប់អារម្មណ៍ មកចាប់អារម្មណ៍បានក៏ព្រោះតែមានការ ឧបត្ថម្ភជ្រំជ្រែងយ៉ាងខ្លាំងខ្លា ពីលោកជំទាវឧញ៉ា ម៉ៅ ម៉ាល័យ កែគឹមយ៉ាន ។







# 11. ខេត្ត កំពង់ចាម




ខេត្តកំពង់ចាម គឺជាខេត្តនៃប្រទេសកម្ពុជាដែលស្ថិតនៅវាលទំនាបកណ្ដាលនៃទន្លេមេគង្គ។ វាមានព្រំប្រទល់ជាប់នឹងខេត្តកំពង់ធ្នាំងនៅខាងលិច កំពង់ធំ និង ក្រចេះនៅខាងជើង ត្បូងឃ្មុំនៅខាងកើត និង ព្រៃវែង និង កណ្ដាលនៅខាងត្បូង។ កំពង់ចាមជាផ្លូវការត្រូវបានបែងចែកទៅជាពីរខេត្តនៅថ្ងៃទី ៣១ ធ្នូ ២០១៣ ជារឿងដែលគេមើលឃើញភាគច្រើនថាជារបត់នយោបាយរបស់បក្សកាន់អំណាច។ ផ្ទៃដីទាំងអស់នៅខាងលិចនៃទន្លេមេគង្គនៅតែជាកំពង់ចាមដដែល គ្រាដែលផ្ទៃដីនៅខាងកើតទន្លេបានក្លាយជាខេត្តត្បូងឃ្មុំ។ មុនការបែងចែកនេះ កំពង់ចាមបានលាតសន្ធឹងទៅខាងកើតដល់ព្រំដែនអន្តរជាតិជាមួយវៀតណាម ធ្លាប់ជាខេត្តធំទី១១នៅកម្ពុជា និងមានប្រជាជន ១ ៦៨០ ៦៩៤ នាក់ ដែលបានចាត់ទុកថាជាខេត្តដែលមានប្រជាជនច្រើនបំផុតទីពីរក្នុងប្រទេស។ ទីរួមខេត្ត និង ក្រុងធំបំផុតរបស់ខេត្តនេះគឺក្រុងកំពង់ចាម។ កំពង់ចាមគឺជាស្រុកកំណើតនៃលោកនាយករដ្ឋមន្ត្រីហ៊ុន-សែនបច្ចុប្បន្ន។



OunNutmini PHOTOGRAPHY

## 1.1 ភ្នំប្រុសភ្នំស្រី

"ភ្នំប្រុសភ្នំស្រី"ជារមណីយដ្ឋានទេសចរណ៍បែបវប្បធម៌ប្រវត្តិសាស្ត្រ រមណីយដ្ឋាននេះមានទីតាំងស្ថិតនៅក្នុងភូមិត្រពាំងចារ ឃុំក្រឡា ស្រុកកំពង់សៀម ដែលមានចំងាយប្រមាណជា ៧គីឡូម៉ែត្រ ពីទីរួមខេត្តកំពង់ចាម នៅទីនេះមានសក្តានុពលទេសចរណ៍សំខាន់ៗដែលទាក់ទងនឹងរឿងព្រេងបុរាណខ្មែរគឺរឿងភ្នំប្រុសភ្នំស្រី។ នៅទីនេះភ្ញៀវទេសចរអាចទស្សនាភ្នំ ប្រសាទបុរាណ ស្តូបឧក្រិដ្ឋកម្មវាលពិឃាត។





## 1.2 នគរបាជ័យ

"នគរបាជ័យ"ជារមណីយដ្ឋានទេសចរណ៍បែបវប្បធម៌ប្រវត្តិសាស្ត្រ រមណីយដ្ឋាននេះមានទីតាំងស្ថិតនៅក្នុងភូមិជង្រុក ឃុំអំពិល ស្រុកកំពង់សៀម ដែលមានចំងាយប្រមាណជា ២គីឡូម៉ែត្រ ពីទីរួមខេត្តកំពង់ចាម នៅទីនេះមានសក្តានុពលទេសចរណ៍សំខាន់ៗដែលទាក់ទងនឹងរឿងព្រេងបុរាណខ្មែរ ចម្លាក់ប្រាសាទ។ នៅទីនេះ ភ្ញៀវទេសចរអាចទស្សនាប្រាសាទបុរាណ ដែលកសាងឡើងនៅដើមសតវត្សទី១៣។









## 1.3 រមណីយដ្ឋានបឹងធំ

"បឹងធំ"ជារមណីយដ្ឋានទេសចរណ៍បែបធម្មជាតិ រមណីយដ្ឋាននេះមានទីតាំងស្ថិតនៅក្នុងភូមិក្តីបឹង ឃុំវិហារធំ ស្រុកកំពង់សៀម ដែលមានចំងាយប្រមាណជា ១៤គីឡូម៉ែត្រ ពីទីរួមខេត្តកំពង់ចាម នៅទីនេះមានសក្តានុពលទេសចរណ៍សំខាន់ៗ មានប៉មមួយសម្រាប់មើលទេសភាព និងជាទីជម្រកសត្វស្លាប។ នៅទីនេះ ភ្ញៀវទេសចរអាចទស្សនាដែនជម្រកសត្វស្លាបជាច្រើន ជីវភាពរបស់ប្រជាជនក្នុងតំបន់ និងគយគន់ទេសភាព។





# 12 ខេត្ត កំពង់ឆ្នាំង

ខេត្តកំពង់ឆ្នាំង ជាខេត្តមួយស្ថិតនៅភាគកណ្ដាលនៃប្រទេសកម្ពុជា។ ខេត្តកំពង់ឆ្នាំង ជាខេត្តល្បីខាងផលិតក្អមឆ្នាំងមានគុណភាពល្អអំពីដី។ ខេត្តជិតខាងគឺ (ពីខាងជើងតាមទ្រនិចនាឡិការិល) កំពង់ធំ កំពង់ចាម កណ្ដាល កំពង់ស្ពឺ និងពោធិ៍សាត់។ ក្រុងទីរួមខេត្តកំពង់ឆ្នាំងគឺក្រុងកំពង់ឆ្នាំង។




## 1.1 ប្រាសាទប្រុស ឬប្រាសាទសក្ត

ទសក្ង ស្ថិតនៅក្នុងភូមិប្រឡូកកើត ឃុំប្រឡូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំងមានចំងាយ១៨គ.ម ពីទីរួមស្រុកកំពង់លែង (គិតតាមផ្លូវពោធិ៍) និងមានចម្ងាយ ៣គ.ម ពីទីស្នាក់ការឃុំប្រឡូក តែបើគិតពីក្រុងកំពង់ឆ្នាំងទៅដល់ទីទួលប្រាសាទមានចម្ងាយ៣១គ.ម។ ប្រាសាទនេះត្រូវបានកសាងឡើងនៅអំឡុងសតវត្សទី៧-៨ បែរមុខទៅទិសខាងកើត។









## 1.2 ប្រាសាទស្រី

ប្រាសាទស្រីស្ថិតនៅក្នុងភូមិប្រាសាទ ឃុំដារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង មានចម្ងាយ ១៦គ.ម ពីទីរួមស្រុកកំពង់លែង និងមានចម្ងាយ ៦គ.ម ពីស្នាក់ការឃុំដារ បើគិតពីក្រុងកំពង់ឆ្នាំងមានចម្ងាយ ២៩គ.ម។ ក្រោយពីបានទស្សនាប្រាសាទនៅភូមិជ្រលងហើយ ភ្ញៀវទេសចរ អាចបន្តដំណើរទៅមុខទៀតតាមផ្លូវកៅស៊ូដែលឆ្លងកាត់ភូមិប្រាសាទ តាមផ្លូវបត់ស្តាំទៅកើតចម្ងាយ ៩៧០ ម៉ែត្រ។ ប្រាសាទស្រីត្រូវបានកសាងឡើងនាអំឡុងសតវត្សទី៧-៨ សាងអំពីឥដ្ឋក្រហម ហើយបែរមុខទៅទិសខាងកើត ។







## 1.3 សហគមន៍អេកូទេសចរណ៍ទឹកធ្លាក់ស្រែអំបិល

សហគមន៍អេកូទេសចរណ៍ទឹកធ្លាក់ស្រែអំពិល ស្ថិតនៅភូមិដំណាក់អំពិល ឃុំក្រាំងស្គារ ស្រុកទឹកផុស មានចម្ងាយប្រមាណ ៦១គ.ម ពីក្រុងកំពង់ឆ្នាំង។ ភ្ញៀវទេសចរអាចទៅ ទស្សនាលំហែកាយ ងូតទឹកលេងនៅពេលសម្រាកពីការងារ ឬថ្ងៃចុងសប្តាហ៍ ស្រស់ស្រូបអាហារជុំគ្រួសារ ឬជួបជុំមិត្តភ័ក្រ្ត នៅក្រោមម្លប់ឈើដ៏ត្រឈឹងត្រឈៃ កម្សាន្តជាមួយនូវទឹកធ្លាក់ដ៏សែនត្រជាក់ លាងជម្រះនូវភាពនឿយហត់ តប់ប្រមល់ និងទុក្ខសោកទាំងឡាយឲ្យទៅតាមទឹក និងនាំមកវិញនូវសេរីសួស្តីត្រលប់មកវិញ។ ក្រោពីនោះ ភ្ញៀវទេសចរអាចកម្សាន្ត នៅតំបន់ភ្នំដែលមានទេសភាពស្រស់បំព្រង  និងមានដើមឈើតូចធ្វើឲ្យភ្ញៀវទេសចរមកកម្សាន្ត ម្តងហើយម្តងទៀតឥតឈប់ឈរ។

# 13 ខេត្ត កំពង់ស្ពឺ





ខេត្តកំពង់ស្ពឺស្ថិតនៅខាងលិចទីក្រុងភ្នំពេញហើយនៅជិតច្រកចូលទីក្រុងភ្នំពេញបំផុត ហើយក៏ជាខេត្តមួយត្រូវបានគេមើលរំលង ប៉ុន្តែជាកន្លែងពិសេសមួយដែលមិនសូវមានចរាចរណ៍ស្មុគស្មាញៗ
កំពង់ស្ពឺជាខេត្តល្បីល្បាញពីការផលិតស្ករត្នោតដែលមានគុណភាពល្អបំផុតនៅក្នុងប្រទេសកម្ពុជា។ ខេត្តនេះក៏ផលិតទឹកត្នោតជូរ និងស្រាទឹកត្នោតជាច្រើនផងដែរ។ ភ្នំឱរ៉ាល់ជាភ្នំខ្ពស់ជាងគេបំផុតដែលមានទីតាំងនៅព្រំដែនខេត្តដូចជា កណ្តាល កោះកុង ពោធិ៍សាត់ តាកែវ និងកំពង់ឆ្នាំង។ ភ្នំនេះមានកម្ពស់១៨១៣ម៉ែត្រពីនីវ៉ោទឹកសមុទ្រ។ "ក្រុងច្បារមន" ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺមានព្រំប្រទល់ខាងជើងទល់នឹងឃុំខ្ពុំត្រាំង និងឃុំញ្ញាយ ស្រុកសំរោងទងខាងត្បូងទល់នឹងឃុំស្គុះ ស្រុកសំរោងទងខាងកើតទល់នឹងឃុំវល្លិស ស្រុកសំរោងទងខាងលិចទល់នឹងឃុំកាហែង និងឃុំធម្មតាអរ ស្រុកសំរោងទង។ មានក្រឡាផ្ទៃដីសរុប៖៨១,៤៤ គម២មាន ០៥ សង្កាត់រួមមាន សង្កាត់រកាធំ, សង្កាត់ច្បារមន, សង្កាត់ស្វាយក្រវ៉ាន់, សង្កាត់សុព័រទេព សង្កាត់ កណ្តោលដុំមានប្រជាជន ៤៨.០៤៩ នាក់ ត្រូវជា ១០.៦០៣ គ្រួសារប្រជាជនភាគច្រើនប្រកបរបរជា កសិកម្ម សេវាកម្ម ឧស្សាហកម្ម និងមន្រ្តីរាជការ

## 1.1 ឧទ្យានជាតិគិរីរម្យ

ឧទ្យានជាតិគិរីរម្យជារមណីយដ្ឋានទេសចរណ៍បែបធម្មជាតិ រមណីយដ្ឋាននេះមានទីតាំងស្ថិតនៅក្នុងភូមិដំរីផុស ឃុំគិរីរម្យ ស្រុកភ្នំស្រួច ដែលមានចំងាយប្រមាណជា៤៤គីឡូម៉ែត្រ ពីទីរួមខេត្តកំពង់ស្ពឺ។ នៅទីនេះមានសក្តានុពលទេសចរណ៍សំខាន់ៗដូចជារមណីយដ្ឋានទឹកជ្រោះភ្នំដំណាក់ចាស់ ដំណាក់ថ្មី តំបន់ស្រះស្រង់ តំបន់ទឹកធ្លាក់ ជ្រោះអូរតាហ៊ុយ តំបន់ចំការតែ ភ្នំថ្មដា និងតំបន់ល្អាងភ្នំៗ។ នៅទីនេះ ភ្ញៀវទេសចរអាចធ្វើអ្វីបានខ្លះងូតទឹកកម្សាន្តញុំាអាហារ ទស្សនាទេសភាពធម្មជាតិ។

## 1.2 អំពែភ្នំ



អំពែភ្នំជារមណីយដ្ឋានទេសចរណ៍បែបធម្មជាតិរមណីយដ្ឋាននេះមានទីតាំងស្ថិតនៅក្នុងភូមិអំពែភ្នំ ឃុំស្វាយក្រវ៉ាន់ក្រុងច្បារមន ដែលមានចំងាយប្រមាណជា២៨គីឡូម៉ែត្រពីទីក្រុងភ្នំពេញ។ នៅទីនេះមានសក្តានុពលទេសចរណ៍សំខាន់ៗដូចជាវត្តចាស់បុរាណមួយនៅលើកូនភ្នំ ដែលជាទីសក្ការៈរបស់ប្រជាពលរដ្ឋ ទៅធ្វើបុណ្យទានតាមប្រពៃណីជាតិ។ នៅទីនេះ ភ្ញៀវទេសចរអាចងូតទឹកឆ្លងស្ពានយោល និង អង្គុយលេងកម្សាន្តតាមតូបនានាសម្រាកតាមមាត់ស្ទឹងដើម្បីលំហែអារម្មណ៍ ហើយនៅតាមតូបនីមួយៗគេអាចកុម្ម៉ង់ម្ហូបសាច់សត្វព្រៃបានតាមចិត្តប្រាថ្នានេះសបញ្ជាក់ថាការលួចបរបាញ់សត្វព្រៃនៅតែមាន។



## 1.3 ខ្នងផ្សារ

តាមរយៈទំព័រហ្វេសប៊ុកមរតកកម្ពុជា រមនីយដ្ឋានធម្មជាតិខ្នងផ្សារជាតំបន់ព្រៃភ្នំដ៏ធំមួយដែលស្ថិតនៅក្នុងភូមិតាំងបំពង តំបន់រលាក់កង់ជើង ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ ខ្នងផ្សារជាទីតាំងប្រសព្វមុំបីដែលផ្សាភ្ជាប់ខេត្តចំនួនបីគឺ កោះកុង កំពង់ស្ពឺ និងពោធិ៍សាត់។ ខ្នងផ្សារ ជាតំបន់មួយដែលសំបូរទៅព្រៃឈើក្រាស់ជ្រលងភ្នំខ្ពស់ៗ វាលស្រល់ដ៏ស្រស់ស្អាត និងសំបូរទៅដោយសត្វព្រៃកម្រជាច្រើនប្រភេទ។ ពេលព្រឹកព្រលឹមយើងគួរធ្វើដំណើរទៅកាន់



ពយខ្នងផ្សារ ដើម្បីទស្សនាភាពស្រស់ស្អាតនៃរស្មីព្រះអាទិត្យរះ អមដោយអាកាសធាតុត្រជាក់ និងពពកហោះយ៉ាងឃ្មួលខ្មាញ់ ។ ពេលល្ងាចយើងអាចទស្សនាថ្ងៃលិចពីលើខ្នងភ្នំផងដែរ ។
















# 14 ខេត្ត កំពង់ធំ

"ក្រុងស្ទឹងសែន"ស្ថិតនៅក្នុងខេត្តកំពង់ធំដែលមានព្រំប្រទល់ខាងជើងទល់នឹង ស្រុកកំពង់ស្វាយហើយមានច្រកចេញចូលចំនួន ២ គឺផ្លូវជាតិលេខ ៦ ខេត្តសៀមរាបនិង ផ្លូវជាតិលេខ ៦២ ខេត្តព្រះវិហារ។ ខាងត្បូងទល់នឹងស្រុកសន្ទុកមានច្រកចេញចូលចំនួន១គឺផ្លូវពីស្រុកប្រាសាទសំបូរនិងស្រុកកំពង់ស្វាយ។ ខាងកើតទល់នឹងស្រុកកំពង់ស្វាយដែលមានច្រកចេញចូលចំនួន១គឺផ្លូវជាតិលេខ៦ខេត្តកំពង់ចាមរាជធានីភ្នំពេញ។ ខាងលិចទល់នឹងស្រុកកំពង់លែងខេត្តកំពង់ឆ្នាំង(តំបន់ទន្លេសាប)ហើយមានច្រកចេញចូលចំនួន១គឺផ្លូវជាតិលេខ៥០C (កំពង់សាងសង់) និងផ្លូវទឹកនៅរដូវវស្សា។ ហើយមានផ្ទៃក្រឡាក្រុងបេក្ខភាព៖ ៣៦៧,៥០ គ.ម២ដែលមាន ៨សង្កាត់គឺសង្កាត់ដំរីជាន់ខ្លាសង្កាត់កំពង់ធំ សង្កាត់កំពង់រទេះ សង្កាត់អូរគន្ធរ សង្កាត់កំពង់ក្របៅ សង្កាត់ព្រៃតាហ៊ូ សង្កាត់អាចារ្យលាក់និងសង្កាត់ស្រយ៉ូវ។ ដែលប្រជាជនសរុប៥៨,៥៧៧នាក់ស្រី២៩,៩៧៥(១៥៨នាក់/គ.ម២។





## 1.1 ប្រាសាទសំបូរព្រៃគុក



ប្រាសាទសម្បូរព្រៃគុកមានទីតាំងស្ថិតនៅក្នុងភូមិសម្បូរ ឃុំសម្បូរ ស្រុកសម្បូរ ខេត្តកំពង់ធំ។ ប្រាសាទនេះស្ថិតនៅតាមបណ្តោយស្ទឹងសែនដែលមានចម្ងាយប្រហែល ២៨គីឡូម៉ែត្រ ភាគឦសាននៃទីរួមខេត្តកំពង់ធំ និងមានចម្ងាយប្រហែល ១៨១គីឡូម៉ែត្រ ពីរាជធានីអង្គរនៃខេត្តសៀមរាប និងមានចម្ងាយប្រហែល១៧០គីឡូម៉ែត្រពីប្រាសាទព្រះវិហារនៃខេត្តព្រះវិហារនិងមានចម្ងាយប្រហែល ១៩៦គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ។ ប្រាសាទសម្បូរព្រៃគុកជាប្រភេទរមណីយដ្ឋានវប្បធម៌ និងប្រវត្តិសាស្ត្រដែលមានមានចម្ងាយប្រមាណ ៣៧គីឡូម៉ែត្រ បត់តាមផ្លូវជាតិ៦៤ បត់ស្តាំតាមសាលាវិស័យកាត់តាមផ្លូវបុសស្រមោច ផ្លូវនេះពេលរដូវវស្សាលិចទឹក តែយើងអាចធ្វើដំណើរឆ្ពោះទៅស្រុកសំបូរបានតែម្តងៗដែលសង់លើដីរាបស្មើមានទំហំ ៣,០០០ ហិកតា។ រមណីដ្ឋានសំបូរព្រៃគុក ជារាជធានីចាស់ឈ្មោះថា ឥសានបុរៈ ពីសម័យនោះជាមជ្ឈមណ្ឌលនៃព្រាហ្មណ៍សាសនា ដើម្បីឧទ្ទិសថ្វាយដល់ ព្រះសិវៈ ឬព្រះឥសូរនិយម។ ក្រុមប្រាសាទនេះសាងសង់អំពីឥដ្ឋតាន់ និង ថ្មបាយក្រៀមលំអរទៅដោយចម្លាក់ពីលើឥដ្ឋ ចាក់ពុម្ពដោយបាយអ ជាផ្ទាំងៗអំពីឥដ្ឋ តែបច្ចុប្បន្នរបេះអស់មួយចំនួន។ ក្បាច់ផ្តែរ និងការសរសេរជាពាក្យពេជ្រ ប្រអប់ទ្វារធ្វើអំពីថ្មភក់ទាំងអស់។ប្រាសាទនេះកសាងឡើងនៅរជ្ជកាលព្រះបាទឥសានវរ្ម័នទី១ នៅក្នុង សតវត្សរ៍ទី៧ (គ.ស៦១៦-៦៣៥) នាសម័យចេនឡាក្រុមប្រាសាទសំបូរព្រៃគុកនេះ ត្រូវបានបោះបង់ចោលតាំងពីឆ្នាំ១៩៧១មកម្ល េះ ហើយត្រូវបានរៀបចំសារជាថ្មីនៅឆ្នាំ១៩៨០។ក្នុងការកាប់ស្ការព្រៃគេរកឃើញមានប្រាសាទទាំងអស់ចំនួន ១៤០ប្រាសាទ ហើយនៅប្រាសាទទៅពីទៀត រកមិនទាន់ឃើញ[១]។ រមណីយដ្ឋានសម្បូរព្រៃគុកចែកចេញជា៤ក្រុមធំៗគឺៈ ក្រុមប្រាសាទខាងជើង ក្រុមប្រាសាទកណ្តាល ក្រុមប្រាសាទខាងត្បូង ក្រុមប្រាសាទក្រោលរមាស។





## 1.2 រមណីយដ្ឋានបឹងសំរឹទ្ធិ

រមណីយដ្ឋានបឹងសំរឹទ្ធិស្ថិតនៅភូមិចុងដូង ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ រមណីយដ្ឋានបឹងសំរឹទ្ធិមានការពេញនិយមពីភ្ញៀវជាតិ និងអន្តរជាតិមកទស្សនាកម្សាន្តរាល់សំណង់ស្ថាបត្យដ្ឋានតាមរចនាបទខ្មែរ។ត្រូវបានសាងសង់ចាប់ពីឆ្នាំ ២០០៦រហូតដល់ឆ្នាំ២០១២ សម្ពោធន៍នៅ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០១៣។



# រមណីយដ្ឋានបឹងសំរឹទ្ធិ





# 15 ខេត្ត កំពត

ខេត្តកំពត ជាខេត្តមួយស្ថិតនៅប៉ែកខាងត្បូងនៃប្រទេសកម្ពុជា ដែលមានចម្ងាយ ១៤៨ គ.ម. ពីទីក្រុងភ្នំពេញ មានព្រំប្រទល់ខាងជើងទល់នឹងស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ខាងកើតជាប់នឹងស្រុកត្រាំកក់ និង ស្រុកគីរីវង់ ខេត្តតាកែវ ខាងត្បូងជាប់នឹងឈូងសមុទ្រ ខាងលិចជាប់នឹងស្រុកកំពង់សិលា និងស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដូចគ្នាដែរ ខ្សែឆ្នេរដ៏វែងស្ថិតនៅលើឈូងសមុទ្រថៃទៅខាងត្បូង ខេត្តកំពតមានទីក្រុងឈ្មោះក្រុងកំពត។ កំពតមានប្រជាជន ៦២៧ ៨៨៤ នាក់ និងប្រកបដោយស្រុកនិងក្រុងចំនួនប្រាំបីដែលបានចែកទៅជាឃុំ-សង្កាត់ ៩២ ជាមួយនិងភូមិសរុប ៤៧៧ នាក់។ ខេត្តកំពតមានសំណង់ប្រវត្តិសាស្ត្រជាច្រើនដូចជា ផ្ទះ ផ្សារលក់ទំនិញ រោងភាពយន្ត សាលារៀន ផ្លូវគមនាគមន៍ មន្ទីរពេទ្យជាដើម សុទ្ធសឹងជាភស្តុតាងបង្ហាញឱ្យឃើញពីការចាប់អារម្មណ៍របស់ពួកបារាំងទៅលើទឹកដីខ្មែរខេត្តកំពតមួយនេះ។ហើយក៏មានភ្នំបូកគោដែលជាទីចាប់អារម្មណ៍របស់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិគ្រប់ៗរូបផងដែរ។ នៅលើនោះក៏មានកាស៊ីណូ និង មានកន្លែងកម្សាន្តជាច្រើនដូចជា៖ វាលស្រែមួយរយ ទឹកធ្លាក់អាចមើលទេសភាពមកខាងក្រោមយ៉ាងស្រស់ស្អាត អាចចាប់ពពកបាន។-ល-។ ស្រុកទូកមាសបានតាំងទីនៅខេត្តកំពត។ទេសភាពនៃព្រែកកំពត មើលពីក្រុងកំពត ក្បែរសាលាខេត្ត ចំពីមុខភ្នំបូកគោ។







## 1.1 ទឹកធ្លាក់ឱម៉ាល់



ទឹកធ្លាក់ឱម៉ាល់ ភ្ញៀវទេសចរអាចមើលឃើញទឹកធ្លាក់នៅខាងឆ្វេងដៃហូររណ្ដំជាមួយដុំថ្មតូចធំ តម្រៀបគ្នាក្នុងជ្រលងអូរ ហើយទឹកដែលហូរធ្លាក់មកនេះគឺបានស្តុកទឹកសម្រាប់អោយភ្ញៀវអាចចុះលេងទឹកយ៉ាងសប្បាយរីករាយដោយមិនភ័យព្រួយខ្លាចគ្រោះថ្នាក់ រួមជាមួយសម្លេងបក្សាបក្សីយំអឺងកង រួមជាមួយនឹងធម្មជាតិដ៏ស្រស់បំព្រង ដើមឈើតូចធំដុះអមផ្លូវទឹកដែលហូរ គឺភ្ញៀវប្រាកដជាបាត់អស់ទាំងទុក្ខកង្វល់។



## 1.2 ឧទ្យានជាតិព្រះមុនីវង្ស បូកគោ



ឧទ្យានជាតិព្រះមុនីវង្សបូកគោ គឺជាឧទ្យានមួយក្នុងចំណោមឧទ្យានជាតិដ៏ស្រស់ស្អាតរបស់ព្រះរាជាណាចក្រកម្ពុជា។ ឧទ្យានជាតិនេះល្បីឈ្មោះដោយសារតែអាកាសធាតុត្រជាក់ពេញមួយឆ្នាំ និងសម្រស់ព្រៃព្រឹក្សាធម្មជាតិដ៏ស្រស់បំព្រងល្អឯកគ្មានគូរប្រដូចក្នុងតំបន់។ នៅលើកំពូលភ្នំភ្ញៀវទេសចរអាចគយគន់ទិដ្ឋភាពនៃទិដ្ឋភាពទីក្រុងកំពត ឆ្នេរសមុទ្រកែបខេត្តព្រះសីហនុ និងកោះជាច្រើនដែលនៅខាងក្រោម។ ភ្នំបូកគោ ត្រូវបានរកឃើញនៅឆ្នាំ1917 ដោយជនជាតិបារាំង និងត្រូវបានអភិវឌ្ឍឱ្យទៅជារមណីយដ្ឋាននៅឆ្នាំ1921 ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ។ នៅអំឡុងពេលនោះ ភ្នំបូកគោ គឺជាទីកន្លែងកម្សាន្តដ៏ល្បីល្បាញសម្រាប់អភិជនបារាំងនិងរាជវង្សានុវង្ស។ ភ្នំបូកគោ ត្រូវបានដាក់ឈ្មោះថាជាឧទ្យានជាតិព្រះមុនីវង្សបូកគោដោយព្រះរាជក្រឹត្យកាលពីឆ្នាំ1993 ដែលមានផ្ទៃក្រឡា 1400គីឡូម៉ែត្រការេ។









MI NOTE 10 PRO
ALPENTA CAMERA

## 1.3 ចម្ការម្រេចភ្នំកូនសត្វ

ចម្ការម្រេចភ្នំកូនសត្វ ជារមណីយដ្ឋានដ៏អស្ចារ្យដែលស្ថិតនៅលើចង្កេះភ្នំ ដែលមានកន្លែងញ៉ាំអាហារ កន្លែងស្នាក់នៅដ៏ប្រណិត មានអាងហែលទឹកយ៉ាងធំ មានខ្យល់ជំនោរដ៏ត្រជាក់បោកបក់ពីឈូងសមុទ្រថៃ មានជួរភ្នំវល្ល៍ដ៏វែងអន្លាយ មានទេសភាពធម្មជាតិស្រស់បំព្រង មានចម្ការច្បារដំណាំ ជាពិសេសចម្ការម្រេចមានពណ៌ខៀវខ្ចី។










# 16 ខេត្តកណ្ដាល

*ខេត្តកណ្ដាលជាខេត្តនៅកណ្ដាលប្រទេសកម្ពុជាដែលព័ទ្ធជុំវិញទីក្រុងភ្នំពេញ។ ទីក្រុងរបស់ខេត្តនេះគឺតាខ្មៅ ខេត្តនេះក៏មានស្រុកឧត្ដុង្គដែលជាអតីតរាជធានីរបស់ប្រទេសនៅចន្លោះឆ្នាំ១៦១៨ និងឆ្នាំ១៨៦៦។ មានព្រះមហាក្សត្រមួយចំនួនគ្រងរាជ្យនៅរាជធានីឧត្ដុង្គ។ ក្រុងតាខ្មៅ ស្ថិតនៅក្នុងខេត្តកណ្ដាលមានព្រំប្រទល់ខាងជើងទល់នឹងរាជធានីភ្នំពេញ ខាងត្បូងទល់នឹង ស្រុកស្អាង ខាងកើតទល់នឹង ទន្លេបាសាក់ ខាងលិចទល់នឹង ស្រុកកណ្ដាលស្ទឹង ។ ហើយមានផ្ទៃក្រឡាក្រុងបេក្ខភាព ៣១,៧៨ គម២ ។ ដែលមាន ០៦សង្កាត់ សង្កាត់តាខ្មៅសង្កាត់ដើមមាន សង្កាត់កំពង់សំណាញ់ សង្កាត់ព្រែកឬស្សី សង្កាត់តាក្ដុលសង្កាត់ព្រែកហូរ។*

## 1.1 ភ្នំព្រះរាជទ្រព្យ

*ភ្នំព្រះរាជទ្រព្យ គឺជារមណីយដ្ឋានទេសចរណ៍បែបវប្បធម៌ប្រវត្តិសាស្រ្ត និងជា បូជនីយដ្ឋានពេញនិយមមួយសម្រាប់ពុទ្ធសាសនិកជន។ ភ្នំព្រះរាជទ្រព្យមានទីតាំងស្ថិតនៅឃុំផ្សារដែក និងឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្ដាល និងមានចំងាយផ្លូវប្រមាណជា៥១ គីឡូម៉ែត្រពីទីរួមខេត្ត។សាវតារប្រវត្តិសាស្រ្តបញ្ជាក់ថា ភ្នំព្រះរាជទ្រព្យគឺជា អតីតរាជធានីនាសតវត្សរ៍ទី ១៧ (ពីឆ្នាំ១៦១៨ ដល់ឆ្នាំ ១៨៦៦)នៃព្រះបាទជ័យជេដ្ឋាទី២ មានឈ្មោះជារាជធានីថា ព្រះបរមរាជវាំងមហានគរឧដុង្គ-មានជ័យបុរីរម្យឧត្តមរាជនិវេសនដ្ឋាន ដែលហៅខ្លីថា ក្រុងឧដុង្គមានជ័យ។ លុះឆ្នាំ១៨៦៦ ក្រុងឧត្តុង្គមានជ័យត្រូវបានបោះបង់ដោយព្រះបាទនរោត្តម ក្រោយពីទ្រង់សព្វព្រះរាជហឫទ័យត្រឡប់មកកសាងរាជធានីចតុមុខមង្គលសារជាថ្មី។រាប់ពីជើង ទៅ ចង្កេះដល់កំពូលភ្នំ ភ្នំព្រះរាជទ្រព្យ ប្រកបដោយបេតិកភណ្ឌជាតិច្រើនសន្ធឹកពិសេសនូវប្រូងភ្នំដ៏ខ្ពស់បានបង្ហាញនូវប្រាង្គទាំងប្រាំនៃចេតិយផុសចេញពីទេសភាពដ៏វែងអន្ទាយ។ភ្នំព្រះរាជទ្រព្យមាននូវគោលដៅទេសចរណ៍*



ជាច្រើនចំណុចដែលមានការរៀបរាប់ពីដំណើរពីចេតិយ៍ស្តេចអង្គមួយទៅអង្គមួយទៀតនៃសម័យលង្វែកឧត្តុង្គ ព្រមទាំងព្រះរាជវង្សានុវង្សវិហារខ្មែរនានា កន្លែងសក្ការៈបូជានៃអតីតមេទ័ពខ្មែរមានមហិទ្ធិរិទ្ធគឺតាដំបងដែក ព្រះសក្យមុនីចេតិយ៍កោដ្ឋមាសនៃសិរីរិកធាតុព្រះពុទ្ធផ្លូវដំណើរនៅក្រោមសក្យមុនីចេតិយ៍មានតម្កល់បដិមាព្រះពុទ្ធតូចៗចំនួន ១២៥០អង្គដែលជាតំណាងព្រះអរហន្តព្រះអង្គដែលទ្រង់បំបួសធំជាងគេនៅថ្ងៃដាក់អាយុសង្ខារ។ ចេតិយ៍ដែលត្រូវបានសាងសង់នៅលើកំពូលភ្នំបានក្លាយជានិមិត្តរូបមួយដែលចែងចាំងនៃម្ចប់ព្រះពុទ្ធសាសនាប្រដូចនឹងជំនាន់អាណាចក្រខ្មែរនាព្រហ្មញ្ញសាសនាដែលតែងតែកសាងប្រាសាទនៅទីខ្ពស់ដូចជាភ្នំតំណាងឱ្យឋាននៃអាទិទេពផងដែរ។ហេតុដូចនេះ បើចង់ចំណាយពេលសិក្សាស្រាវជ្រាវច្បាស់លាស់ពីប្រវត្តិសាស្ត្រនិងកម្សាន្តទៀតនោះភ្នំព្រះរាជទ្រព្យមួយនេះអាចត្រូវឱ្យអ្នកទេសចរជាតិក៏ដូចជាអន្តរជាតិហោចណាស់ក៏ប្រើពេលវេលាកន្លះថ្ងៃទៅមួយថ្ងៃដែរ។





## 1.2 ភ្នំប្រសិទ្ធិត្បូង



ភ្នំប្រសិទ្ធិត្បូងជារមណីយដ្ឋានទេសចរណ៍បែបធម្មជាតិ។រមណីយដ្ឋាននេះមានទីតាំងស្ថិតនៅក្នុងភូមិប្រសិទ្ធ ឃុំម្កាក់ ស្រុកអង្គស្នួលដែលមានចំងាយប្រមាណជា ៣៧គីឡូម៉ែត្រពីទីរួមខេត្ត។ នៅទីនេះ ភ្ញៀវទេសចរអាចគយគន់ទេសភាពធម្មជាតិ និងបរិភោគអាហារដ៏ឈ្ងុយឆ្ងាញ់។

## 1.3 រមណីយដ្ឋានគៀនស្វាយក្រៅ



រមណីយដ្ឋានគៀនស្វាយក្រៅជារមណីយដ្ឋានធម្មជាតិ ស្ថិតនៅក្នុងឃុំ ភូមិធំ ស្រុកគៀនស្វាយ ចម្ងាយផ្លូវសរុបពីភ្នំពេញ ១៩ គ.ម។ នៅទី នោះមាន វត្តមួយដែលមានឈ្មោះថា វត្តគៀនស្វាយក្រៅ។ ដើម្បីទៅដល់វត្តនោះអ្នកទេសចរត្រូវធ្វើដំណើរតាមដង ផ្លូវជាតិលេខ ១ ដោយឆ្លងកាត់ស្ពានព្រះមុនីវង្សលុះទៅដល់គីឡូម៉ែត្រលេខ ១៩ មានផ្លូវលំនៅខាងឆ្វេងដៃ ដែល មានក្លោងទ្វារបញ្ជាក់ថា វត្តគៀនស្វាយក្រៅ ។ បន្តតាមផ្លូវលំនោះ ចំងាយប្រហែល ៣០០០ម៉ែត្រ ទៀតនឹងទៅ ដល់ទីអារាមនោះ។ ចេញដំណើរហួសពីវត្តប្រមាណជា ១០០ ម៉ែត្រ យើងឃើញកន្លែងកម្សាន្តមួយ ដែលត្រូវគេស្គាល់ថា "គៀនស្វាយ" នោះ ។មណីយដ្ឋាននេះមានផ្ទៃដី ១០ ហិចតា កើតឡើងនៅក្រោយឆ្នាំ ១៩៧៩ ដោយសារទីនេះមានសម្រស់ ធម្មជាតិដ៏អស្ចារ្យ លំអដោយម្ចប់ឈើខ្ពស់ៗ តូចធំ ដ៏ត្រជាក់ត្រឈឹងត្រឈៃ និងមានដំណាំចំការនិង ដំណាំហូបផ្លែគ្រប់មុខដ៏ស្រស់បំព្រងទៀត ។ ក្រៅពីនេះ នៅមានសម្រស់ខ្ទបដ៏វិសេសវិសាលមួយទៀត ដែលបែកចេញពីទន្លេមេគង្គកាត់ទឹកដីដ៏សំបូរជីវជាតិ និងចំការរុក្ខជាតិដ៏ស្តុកស្តម ។ ទន្លេនេះ ហាក់ដូចជាប្រគល់ខ្លួនទាំងស្រុងដល់អ្នកស្រុកនៅទីនេះ ក្នុងការប្រកបរបរដាំដុះ និង រស់នៅក្នុងក្តីសង្ឃឹម ។ ដើមរុក្ខជាតិហូបផ្លែតូចធំបានដុះទោរ ទន់ទោរកផ្ទៃទឹកប្រប និង ឆ្នេរទន្លេខ្ទបហើយបែកមែកត្រសុំត្រសាយចោលម្លប់ដ៏ធំល្វឹងល្វើយ ជាទីមនោរម្យសំរាប់ ភ្ញៀវទេសចរដែលមកកម្សាន្ត ។ ទន្លេខ្ទបនេះ ជាចំណុចសំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរទាំងក្នុង និងក្រៅប្រទេសឲ្យមកកម្សាន្ត ព្រោះទីនេះមានខ្យល់អាកាសបរិសុទ្ធ និងសម្រស់ធម្មជាតីដ៏ស្រស់បំព្រង ។ម្យ៉ាងទៀតរមណីយដ្ឋាននេះមានការទាក់ទាញភ្ញៀវផងដែរ ដោយសារមានផ្ទះបណ្តែតទឹក អាហារដ្ឋាន និងល្បែងកម្សាន្តផ្សេងៗពីព្រោះនៅទីនោះមានឱជារសដ៏ឈ្ងុយឆ្ងាញ់នៃម្ហូបអាហារដូចជាមាន់ដុត ត្រីអាំង និងដំណាំហូបផ្លែដូចជា ខ្នុរ ល្មុត ស្វាយ ចេក ដូង... ។ល ។ ដោយអំនោយផលពីធម្មជាតិ ធ្វើឲតំបន់ទេសចរណ៍គៀនស្វាយនេះមាន

ឥទ្ធិពលទាក់ទាញភ្ញៀវដូចជាផ្ទះទឹក
មានច្រើនតាមមាត់ទន្លេ ។









# 17 ខេត្ត ឧត្តរមានជ័យ

## 1.1 ប្រាសាទតាក្របី



ប្រាសាទតាក្របីជាស្ថាបត្យកម្មខ្មែរចាប់ពីសតវត្សទី១១ ដល់ទី១៣។ ក្នុងរាជព្រះបាទសូយ៌្យវម៌្មទី១ និងព្រះបាទឧទយាទិត្យវម៌្មទី២ ដើម្បីឧទ្ទិសដល់ព្រះឥសូរ ដូចគ្នាទៅនឹងប្រាសាទព្រះវិហារ ប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច ដែលស្ថិតនៅលើជួរភ្នំដងរែក។ កេរ្តិ៍ឈ្មោះប្រាសាទនេះចាប់ផ្ដើមល្បីល្បាញក្រោយពេលមានការចុះផ្សាយរបស់បណ្ដាញសារព័ត៌មានក្នុងពេលកាលពីប៉ុន្មានសិបឆ្នាំមុនថា កងទាហានកម្ពុជា និងថៃ មានការវាយប្រយុទ្ធគ្នា ដើម្បីគ្រប់គ្រងប្រាសាទតាក្របីនេះ។ នៅលើប្រាសាទតាក្របី មានទាហានថៃ និងទាហានខ្មែរយាមល្បាតការពារនៅតំបន់នោះ ពីព្រោះប្រាសាទនោះនៅកៀកព្រំប្រទល់ដែនកម្ពុជា-ថៃ។ បើសិនជាអ្នកចង់មើលប្រាសាទជាជនជាតិខ្មែរ ហើយចូលទៅតាមច្រកផ្លូវពីប្រទេសខ្មែរ ពេលទៅដល់ គឺទាហានខ្មែរជាអ្នកជូនដំណើរមើលប្រាសាទ និងដើម្បីប្រាប់ដំណឹង អំពីកន្លែងណា ដែលអាចទៅបាន និងកន្លែងណាដែលមិនអាចទៅបាន ពីព្រោះទីនោះជាតំបន់ទាហានគ្រប់គ្រង។ប្រកពឯកសារជាច្រើនបានអះអាងថា ប្រាសាទនេះជារបស់ខ្មែរ។

## 1.2 អាតោដូងចិត្ត



អាតោដូងចិត្ត ឬក៏គេច្រើនហៅថា ទំនប់អាងទឹកស្ទឹងស្រែង មានទីតាំងស្ថិតនៅភូមិអាតោ ឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ និងមានចម្ងាយប្រហែល ~65km ពីផ្សារវត្តង់មូលអន្លង់វែង។

អាតោដូងចិត្ត ស្ថិតនៅក្នុងប្រភេទ៖ ទេសចរណ៍កែច្នៃឬរមណីយដ្ឋានកែច្នៃ, ទេសចរណ៍ធម្មជាតិ។ រីឯចំណុចសំខាន់ៗនៅអាតោដូងចិត្ត មានដូចជា៖ ជិះទាទឹក, ជិះទូក, រៀបចំអាហារដោយខ្លួនឯង, លេងទឹកឬហែលទឹក, គយគន់ថ្ងៃលិច, ម្ហូប និងចំណុចផ្សេងៗទៀត។ រមណីយដ្ឋាន អាតោដូងចិត្ត ឬ ទំនប់អាងទឹកស្ទឹងស្រែង ពេលនេះកំពុងទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិជាច្រើនឱ្យចូលទៅទស្សនានៅទីនោះជារៀងរាល់ថ្ងៃ ហើយជាពិសេសនោះគឺថ្ងៃឈប់សម្រាកតែម្តង ជួនកាលមានភ្ញៀវទេសចរទៅកម្សាន្តនៅទីនោះ ពី ២០០០នាក់ទៅ ៥០០០នាក់ ក្នុង១ថ្ងៃៗ។ មូលហេតុ ដែលនាំឱ្យ រមណីយដ្ឋានអាតោដូងចិត្ត មានភាពទាក់ទាញ ដោយសារតំបន់នោះមានកន្លែងហែលទឹកដ៏ល្អ មានជម្រៅដល់៣០ម៉ែត្រ សំបូរទៅដោយត្រីធម្មជាតិធំៗ ធ្វើឱ្យភ្ញៀវទេសចរចង់ហែលទឹកលេងកម្សាន្ត។ លើសពីនេះទៅទៀតនៅទីនោះមានខ្យល់អាកាស ល្អបរិសុទ្ធ ជាប់នឹង ដើងភ្នំអាតោនោះទៀតផង។



## 1.3 ទឹកធ្លាក់ អូរស្វាយ

ទឹកធ្លាក់ អូរស្វាយ មានទីតាំងស្ថិតនៅ ភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ និងមានចម្ងាយប្រហែល ~31km ពីផ្សាររង្វង់មូលអន្លង់វែង។
ទឹកធ្លាក់ អូរស្វាយ ស្ថិតនៅក្នុងប្រភេទ៖ ទឹកជ្រោះឬទឹកធ្លាក់, ព្រៃភ្នំ។ រីឯចំណុចសំខាន់ៗនៅ ទឹកធ្លាក់ អូរស្វាយ មានដូចជា៖ ឡើងភ្នំ, រៀបចំអាហារដោយខ្លួនឯង, លេងទឹកឬហែលទឹក, ដើរលេងដោយថ្មើរជើង, ទស្សនាទេសភាពព្រៃភ្នំ និងចំណុចផ្សេងៗទៀត។កន្លែងមួយដ៏ស្រស់ស្អាត និងគួរអោយចាប់អារម្មណ៍ ព្រោះទឹកធ្លាក់មានច្រើនដំណាក់កាល តាំងពីលើកំពូលភ្នំមកដល់ជើងភ្នំ។ វាជាកន្លែងសាកសមសម្រាប់អ្នកចូលចិត្តការថតរូប និងអ្នកដែលចូលចិត្តការដើរលេងបែបផ្សងព្រេង។មានចំនុចពិបាកមួយចំនួនសម្រាប់ទៅកំសាន្តនៅទីនោះ បើគ្រាន់តែចង់ទៅកំសាន្ត លេងទឹកនៅជើងភ្នំមិនជាបញ្ហានោះទេ ប៉ុន្តែការចង់ទៅអោយដល់ទឹកធ្លាក់ធំលើកំពូលភ្នំ ត្រូវឡើងតាមផ្លូវកាត់ព្រៃ មានថ្មរដិបរដុប និង រអិលដោយអន្ទើ។ ការឡើងទៅលើភ្នំទាមទារអ្នកមានកាយសម្បទារឹងមាំ និងមានលទ្ធភាពជាមធ្យម ដែលអាចដើរព្រៃបាន។ទឹកធ្លាក់ដំណាក់ខ្លះក៏មានគ្រោះថ្នាក់ណាស់ដែរ ព្រោះមានស្លែរច្រើន ហើយជាធម្មតា នៅពេលមានភ្លៀងធ្វើអោយកម្លាំងទឹកធ្លាក់ខ្លាំង



# 18 ខេត្ត ប៉ៃលិន

## 1.1 រមណីយដ្ឋានទឹកធ្លាក់អូរតាវៅឬទឹកធ្លាក់ភ្នំខៀវ



### ទីតាំង

រមណីយដ្ឋានទឹកធ្លាកអូរតាវៅ ឬទឹកធ្លាក់ភ្នំខៀវ មានទីតាំងស្ថិតនៅក្នុងសង្កាត់អូរតាវៅ ខ័ណ្ឌប៉ៃលិន មានចំងាយ ៥គម ពីក្រុងប៉ៃលិន។

### ទិដ្ឋភាពទូទៅ

រមណីយដ្ឋានទឹកធ្លាក់អូរតាវៅ ឬទឹកធ្លាក់ភ្នំខៀវ ជារមណីយដ្ឋានទេសចរណ៍ធម្មជាតិដើម្បីទៅដល់ទីនេះ ភ្ញៀវទេសចរត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ៥៧ រហូតដល់ស្ពានថ្មអូរតាវៅឡើងទៅប្រហែលជាង ១០០ ម៉ែត្រក្នុងខេត្តប៉ៃលិននោះ និងឃើញផ្លាកសញ្ញាបង្ហាញទីតាំងត្រង់មុំផ្លូវបំបែកភូមិខ្ពង់ ពីខាងឆ្វេងដៃ ហើយបត់ចូលទៅប្រមាណ ៧ គីឡូម៉ែត្រទៀត និងដល់កន្លែងរមណីយដ្ឋានធម្មជាតិទឹកថ្លាក់ក្បាលអូរតាវៅហើយ។ រមណីយដ្ឋាននេះមានស្ទឹងធម្មជាតិទឹកថ្លា មានជ្រោះទឹកហូរធ្លាក់លើល្បាក់ថ្មដា យ៉ាងខ្ពស់ ខ្យល់អាកាសត្រជាក់ដល់ក្រអៅបេះដូងដែលធ្វើឲ្យភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ទៅលេងសប្បាយរីករាយ។ ពិសេសនោះ គឺម្ចាស់វិនិយោគបានកែច្នៃខ្ទមសកន្លែងអង្គុយលេងនៅក្បែរមាត់ស្ទឹងអូរតាវៅជាច្រើនកន្លែង មានខ្ទមសអង្គុយនៅខាងលើច្រាំង និងខាងលើកន្លែងចតឡាន សម្រាប់ភ្ញៀវទេសចររង់ចាំក្រុមគ្រួសារចុះទៅលេងទឹកជ្រោះធ្លាក់បែកផ្កាត្រែង។ ចំណែកកន្លែងទុកដាក់ឡានម៉ូតូយ៉ាងស្រួលដែលមិនធ្វើឲ្យមានការព្រួយបារម្ភពីសុវត្ថភាពបាត់បង់អ្វីឡើយ។

## 1.2 រមណីយដ្ឋានកែច្នៃ រហាត់ទឹក

រមណីយដ្ឋានរហាត់ទឹក គឺជារមណីយដ្ឋាន កែច្នៃធម្មជាតិ ស្ថិតក្នុងភូមិសួនអំពៅលិច សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន។ រមណីយដ្ឋាននេះ មានចំងាយផ្លូវប្រហែលជាង ២គីឡូមែត្រ ពីវិមានឯករាជ្យ ដោយត្រូវធ្វើដំណើរចេញពីវិមានឯករាជ្យ ឆ្ពោះមកទិសខាងជើង កាត់តាមពោធិមារាម ហៅវត្តប៉ាហ៊ី ។ បើយើងគិតចាប់ពីវត្តប៉ាហ៊ី មកជើងត្រង់ប្រហែលជាង១គីឡូម៉ែត្រ, មានផ្លូវបំបែកមួយនៅខាងស្តាំដៃ ដោយមានផ្លាកថា រមណីយដ្ឋានរហាត់ទឹក នៅទីនោះ។ ធ្វើដំណើរតាមផ្លូវលំនោះ ប្រហែលជាង ១០០មែត្រ នឹងមកដល់រមណីយដ្ឋានរហាតក។រមណីយដ្ឋានរហាត់ទឹកស្ថិតនៅតាមអូរធម្មជាតិ មានទឹកថ្លាឆ្វេង ហូរមិនចេះដាច់ ខួបប្រាំង ខួបវស្សា ។ មានកសាងខ្ទះស្រស់ស្អាត មានផាសុ

ខភាព នៅតាមមាត់អូរ សំរាប់ភ្ញៀវទេសចរណ៍អង្គុយកំសាន្ត ស្រស់ស្រូបអាហារ ជួបជុំមិត្តភក្តិ ក្រុមគ្រួសារ។ នៅក្នុងអូរមានកសាងទំនប់បង្ហៀរទឹក និងមានរហាត់ទឹកមួយដ៏ធំ មួយនៅចំកណ្ដាល ដែលកាលពីអតីតកាល រហាត់ទឹកនេះ គឺជាវារីអគ្គីសនី សំរាប់យកភ្លើងប្រើប្រាស់នៅក្នុងភូមិក្បែរៗនោះ។ បច្ចុប្បន្ននេះ មានទឹកជ្រៅគួរសម សំរាប់លោតលេងកំសាន្ត ,ជិះទូក, ជិះពោងកំសាន្ត ជាដើម។ លើសពីនេះ រមណីយដ្ឋានរហាត់ទឹកក៏មានអាងទឹកកែច្នៃសំរាប់ហែលលេងកំសាន្ត មានសួនច្បារ ប្រកបដោយផ្កាចំរុះ និងមានរូបសំណាកសត្វព្រៃធម្មជាតិជាច្រើនសំរាប់គយគន់។ ភ្ញៀវទេសចរណ៍ទាំងឡាយ ដែលទៅលេងកំសាន្តនៅ រមណីយដ្ឋានរហាត់ទឹក តែងតែមានអារម្មណ៍សប្បាយរីករាយ ហូបអាហារយ៉ាងឆ្ងាញ់ពិសារជាមួយមិត្តភ័ក្ត ក្រុមគ្រួសារ ជាមួយនឹងអាហារពិសេសៗប្រចាំនៅ រមណីយដ្ឋានរហាត់ទឹក មានដូចជា៖ មាត់ជុត សម្លម្ជូរព្រៃទាបុកទឹកគ្រឿង ជាដើម ដែលមានតម្លៃសមរម្យដូចទៅនឹងតម្លៃនៅលើទីផ្សារធម្មតា៕













# 19 ខេត្ត ព្រៃវែង

ខេត្តព្រៃវែងនៅតំបន់ភាគឦសាន តំបន់ទេសចរណ៍ដែលល្បីជាងគេនៅព្រៃវែងមាន៖

## 1.1 ចុងប៉មកន្លែងមើលថ្ងៃលិចស្អាតបំផុត



ក្រុងព្រៃវែង ត្បិតខ្វះកន្លែងកម្សាន្តមែន តែមានកន្លែងមួយដែលមើលថ្ងៃលិចស្អាតបំផុត បើបានឃើញហើយដឹងតែជាប់ចិត្តស្ទើរដកមិនរួច។ នោះគ្មានអីក្រៅពី ចុងប៉ម ល្បីប្រចាំក្រុងព្រៃវែងនោះឡើយ។ អមដោយទេសភាពថ្ងៃលិចនារដូវទឹកឡើងដែលមិនចាញ់ភ្នំក្រោមនិងភ្នំបាខែង ខេត្តសៀមរាប នោះទេ អ្នកក្រុងព្រៃវែង ទាំងសិស្ស ទាំងអ្នកធម្មតាតែងមកទីនេះស្រូបយកខ្យល់បរិសុទ្ធនៃក្លិនទឹកទន្លេ ត្រជាក់ស្វាងអស់ខួរក្បាល។ ឯខែប្រាំងវិញ គេនៅតែស្រូបខ្យល់បរិសុទ្ធត្រជាក់ តែអមដោយទេសភាពវាលស្រែប្រាំងវិញម្ដងជំនួសលើផ្ទៃទឹកនាខែវស្សា។





### ទិដ្ឋភាពទូទៅ

ចុងប៉ម ស្ថិតនៅក្នុងប្រភេទរមណីយដ្ឋាន ទេសចរណ៍កែច្នៃឬរមណីយដ្ឋានកែច្នៃ។ សម្រាប់ចំណុចសំខាន់ៗ ក៏ដូចជាភាពទាក់ទាញនៃរមណីយដ្ឋានចុងប៉មដែលអាចធ្វើអោយភ្ញៀវទេសចរមានចំណាំ អារម្មណ៍នោះ មានដូចជា៖ ដើរលេងដោយថ្មើរជើង, ស្ទូចត្រី, គយគន់ថ្ងៃលិច និងចំណុចផ្សេងៗ ទៀត។សម្រាប់ការធ្វើដំណើរដើម្បីទៅដល់ទីតាំងនៃរមណីយដ្ឋានចុងប៉ម ភ្ញៀវទេសចរមានភាព ងាយស្រួល ពីព្រោះមិនមានការធ្វើដំណើរថ្មើរជើង និងធ្វើដំណើរឆ្លងទឹក រឺក៏ជិះទូកឡើយ។ ចំពោះ ចំណតរថយន្តវិញ ភ្ញៀវទេសចរអាចធ្វើការចតដោយផ្ទាល់នៅរមណីយដ្ឋានបានថែមទៀតផង។ សម្រាប់កន្លែងអង្គុយលំហែរកាយវិញ រមណីយដ្ឋានចុងប៉ម គឺពុំទាន់មានខ្យសអង្គុយ រឺក៏តូបអង្គុយ សម្រាប់ទទួលភ្ញៀវទេសចរនោះទេ។ ក្រៅពីនេះ រមណីយដ្ឋានចុងប៉មពុំទាន់មានកន្លែងកម្មង់អាហារ រឺកន្លែងលក់អាហារ, អាហារដ្ឋាន និងភោជនីយដ្ឋាននៅឡើយទេ។

## 1.2 រមណីយដ្ឋាននគរភ្នំ(រមណីយដ្ឋានបាភ្នំ)

### ទីតាំង

រមណីយដ្ឋាននគរភ្នំ (រមណីយដ្ឋានបាភ្នំ) មានទីតាំងស្ថិតនៅលើដងភ្នំឈើកាច់ ក្នុងឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង មានចម្ងាយប្រមាណជាង២០គីឡូពីទីរួមខេត្តព្រៃវែង និង៧០គីឡូពីរាជធានីភ្នំពេញ ដោយធ្វើដំណើរតាមកំណាត់ផ្លូវជាតិលេខ១ និងបត់ចូលត្រង់ចំណុចផ្លូវកែងផ្សារកំពង់សឹង្ហ ក្នុងឃុំកំពង់សឹង្ហ ស្រុកព្រះស្ដេច ។

### ទិដ្ឋភាពទូទៅ

រមណីយដ្ឋាននគរភ្នំ(រមណីយដ្ឋានបាភ្នំ) ពោលពេញទៅដោយ បរិយាកាសធម្មជាតិ មានខ្យល់បរិសុទ្ធ ព្រៃឈើ និង វាលស្រែពណ៌ខៀវស្រងាត់នៅជុំវិញ។លក្ខណៈពិសេសមួយទៀតគឺ រមណីយដ្ឋាន នគរភ្នំជាតំបន់ស័ក្តសិទ្ធិមួយ ដែលប្រជាពលរដ្ឋរួមទាំងភ្ញៀវជាតិ និង អន្តរជាតិ ពីគ្រប់ទិសទីមកលេងកម្សាន្តជាប្រចាំ ជាពិសេសគឺនៅរដូវបុណ្យទានម្តងៗ។ មិនតែប៉ុណ្ណោះប្រជាពលរដ្ឋ រស់នៅតំបន់នេះតែងតែមានការជួបជុំគ្នា ដើម្បីប្រារព្ធពិធីបុណ្យឡើងអ្នកតាមួយដែលមានតាំងពីដូន តាមកម្ល៉េះ ឈ្មោះថា អ្នកតា មេសរ ដែលពិធីនេះប្រព្រឹត្តទៅមានរយៈពេល ៣ថ្ងៃ ក្នុងគោលបំណង ដើម្បីរលឹកគុណដល់បុព្វបុរស សុំសេចក្តីសុខ សុំទឹកភ្លៀង និង ការពារប្រជាពលរដ្ឋទាំងអស់ នៅក្នុងភូមិ។រមណីយដ្ឋានបាភ្នំ មានភ្នំ ៤ នៅផ្តុំគ្នាដែលរួមមាន ភ្នំសំពៅ ភ្នំល្អាង ភ្នំធំ និងភ្នំបញ្ញារ។ បាភ្នំ ជាអតីតរាជធានីចាស់ឈ្មោះថា «នគរភ្នំ» ស្ថិតនៅក្បែរភ្នំទាំងឡាយក្នុងស្រុកបាភ្នំ ដែលបច្ចុប្បន្ន នៅបន្សល់ស្នាមខ្លះៗប៉ុណ្ណោះ ដូចជាប្រាសាទបុរាណមួយឈ្មោះថា ប្រាសាទច័ន្ទ ស្ថិតនៅចំពីមុខ វត្តវិហារគុកក្បែរជើងភ្នំសំពៅ ក្នុងឃុំជើងភ្នំ។ បាភ្នំមានទេសភាពល្អ និងមានផ្ទាំងថ្ម រូងថ្មធំៗ ដែលជា






## 1.3 ប្រសាទព្រៃដើមស្រុក

*ទីតាំង*

ប្រាសាទព្រៃដើមស្រុក ឬប្រាសាទព្រះធាតុរាជ មានទីតាំងស្ថិតនៅភូមិបឹងជ័រ ឃុំព្រៃទឹង ស្រុកស៊ីធរកណ្ដាល ប្រមាណ ៣៨គីឡូម៉ែត្រ ពីទីរួមខេត្តព្រៃវែង។

*ទិដ្ឋភាពទូទៅ*

ប្រាសាទព្រៃដើមស្រុក ឬប្រាសាទព្រះធាតុរាជ គឺជាប្រាសាទបុរាណតែមួយគត់ នៅក្នុងខេត្តព្រៃវែង ដែលនៅមានរូបរាង មកទល់បច្ចុប្បន្ន។ ប្រាសាទនេះ មានទីតាំងស្ថិតនៅភូមិបឹងជ័រ ឃុំព្រៃទឹង ស្រុកស៊ីធរកណ្ដាល។ ប្រាសាទបុរាណមួយនេះ ធ្វើពីដីឥដ្ឋ និងថ្មភក់ មានសភាពទ្រុឌទ្រោម និងមានឫសដើមជ្រៃ ព័ទ្ធព្រួប្រាសាទ។ ក្រៅពីសម្បត្តិវប្បធម៌មួយនេះ ខេត្តព្រៃវែង ក៏មានសំណង់បុរាណផ្សេងទៀតផងដែរ ដែលនៅសេសសល់។



20 ខេត្តស្វាយរៀង

## 1.1 រមណីយដ្ឋានប្រាសាទព្រៃបាសាក់

ព្រៃបាសាក់ ឬព្រៃប្រាសាទ មានទីតាំងស្ថិតនៅក្នុងភូមិបាសាក់ ឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងមានចម្ងាយ ៨.៥គីឡូម៉ែត្រ ពីទីរួមខេត្តស្វាយរៀង។ ភ្ញៀវទេសចរអាចធ្វើដំណើរដោយរថយន្តតាមផ្លូវបេតុង ប៉ុន្តែនៅរដូវវស្សាក៏អាចធ្វើដំណើរតាមផ្លូវទឹកនៃដងទន្លេវ៉ៃគោ ក្នុងចម្ងាយត្រឹមតែ៥គីឡូម៉ែត្រប៉ុណ្ណោះ។ ព្រៃបាសាក់មានផ្ទៃដីសរុប ៩ហិកតា ២៤អា និង៩៨សង់ទីអា មានព្រំប្រទល់ខាងជើង និងខាងកើតជាប់នឹងទន្លេវ៉ៃគោ ខាងត្បូង និងខាង លិចជាប់នឹងភូមិអ្នកស្រុក។

នៅចំកណ្តាលព្រៃបាសាក់មានប្រសាទចំនួនពីរ គឺទួលប្រសាទ និងទួលគក់សំពៅ ទួលទាំងពីរនេះឃ្លាតគ្នាប្រវែងប្រមាណ១០០ម៉ែត្រតែប៉ុណ្ណោះ ចំណែកឯទួលប្រសាទ គឺមានសេសសល់«ទួលប្រាងប្រាសាទ» មួយចំហៀង មានកម្ពស់ ២ម៉ែត្រ បណ្តោយ៥ម៉ែត្រ សង់ឡើងពីឥដ្ឋធំៗ។ ប្រាង្គប្រសាទនេះសាងឡើងប្រហែលសតវត្សទី៦ រចនាបទសំបូរព្រៃគុហ៍មកម្ទេះ ហើយលើទួលប្រាសាទនេះដែរសុទ្ធសឹងជាគ្រឹះថ្ម ដែលបានតម្រៀបជាថ្នាក់ៗ ជាប្រភេទថ្មបាយក្រៀម និងដុំឥដ្ឋធំៗ។ ចំណែកទួកគក់សំពៅ មានសណ្ឋានដូចជា សំពៅវែងប្រវែងប្រមាន ២៥ម៉ែត្រ កម្ពស់ ៤ម៉ែត្រ ចំណែកឯជាយសងខាងនៃទួលមានតម្រៀបដោយថ្មបាយក្រៀម និងដុំឥដ្ឋជាថ្នាក់ៗផងដែរ។








## 1.2 រមណីយដ្ឋានធម្មជាតិព្រៃគគីរ

ព្រៃគគីរ គឺជារមនីយដ្ឋានធម្មជាតិដែលសម្បូរទៅដោយដើមគគីរជាច្រើនដើមដុះព័ទ្ធជុំវិញ មានទីតាំងស្ថិតនៅក្នុងបរិវេណ សហគមន៍ ព្រៃឈើចម្ការកូនគគីរ ក្នុងភូមិត្រពាំងផ្លុង សង្កាត់បាទី ក្រុងបាវិត ខេត្តស្វាយរៀង និងចម្ងាយ៣២គីឡូម៉ែត្រពីទីរួមខេត្តស្វាយរៀង។ភ្ញៀវទេសចរអាចធ្វើដំណើរទៅទីនោះបានដោយចំណាយពេលត្រឹមតែ ៣០នាទីប៉ុណ្ណោះ។ នៅទីនោះមានស្រះទឹកធំមួយនៅចំកណ្តាលព្រៃ មានរុក្ខជាតិតូចធំដុះពេញព្រៃមានដូចជា ដើមគគីរ ដើមស្នាច់ និងមានការរៀបចំសង់ជាស្ពានសម្រាប់ដើរទស្សនាព្រៃអាកាសស្បា និងសួនផ្កាចម្រុះពណ៌លម្អយ៉ាងស្រស់បំព្រង ។

នៅរមណីដ្ឋានព្រៃគគីរក៏មានលក់អាហារ ដ៏មានរសជាតិឆ្ងាញ់តាមបែបធម្មជាតិ ដែលបានមកតាមរយៈការផ្គត់ផ្គង់ពីកសិករ មានបន្លែ ត្រី មាន់ និងទា ជាហេតុធ្វើឲ្យប្រជាពលរដ្ឋនៅទីនោះ ទទួលបានប្រាក់ចំណូលតាមរយៈរមណីដ្ឋាននេះដែរ។



## 1.3 ស្ពានព្រែកត្នោត

គឺជារមណីយដ្ឋានបែបធម្មជាតិនិងកែច្នៃមួយដែលខណ្ឌព្រំប្រទល់គ្នាដោយព្រែកត្នោត និងតភ្ជាប់គ្នាដោយស្ពានត្នោត (ពីមុនស្ពានឈើ បច្ចុប្បន្ន ស្ពានដែកបេឡេ)។ ដោយភ្ញៀវទេសចរអាចធ្វើដំណើរចេញពីក្រុងស្វាយរៀងឆ្ពោះទៅទិសខាងលិច តាមផ្លូវជាតិលេខ១ គឺស្ថិតនៅខាងត្បូងសាកលវិទ្យាល័យស្វាយរៀង ចម្ងាយប្រមាណជាង ២គីឡូម៉ែត្រ ហើយទីតាំងនេះគឺស្ថិតនៅត្រើយខាងជើងក្នុងភូមិញ្ញៅ ឃុំតាសួស ស្រុកស្វាយជ្រំ ឬអាចធ្វើដំណើរតាមផ្លូវលំលេខ ៣១៤B ខាងលិច ក្រុងស្វាយរៀងប្រហែល ៤គីឡូម៉ែត្រ ទីតាំងនេះគឺនៅត្រើយខាងត្បូង ស្ថិតក្នុងភូមិឫស្សីព្រៃ ឃុំកំពង់ចម្លង ស្រុកស្វាយជ្រំដូចគ្នាផងដែរ។

រមណីយដ្ឋានស្ពានព្រែកត្នោត មានទេសភាពស្រស់បំព្រង មានខ្យល់អាកាសបរិសុទ្ធបែបស្រុកស្រែចម្ការ មានរុក្ខជាតិតូចធំនានា និងព្រៃឈើពិសេសដើម អាកាស្យា ដុះអមសងខាងផ្លូវមានពណ៌បៃតងខ្ចីផ្តល់ម្លប់យ៉ាងត្រជាក់ត្រឈឹងត្រឈៃ និងមានខ្ទះជាច្រើនផុសអណ្តែតលើផ្ទៃទឹកលាយឡំនឹងឈូក ព្រលិត រំចង់ កញ្ឆែត កំពុងចេញផ្ការីកស្គុះស្គាយ។

ខណៈភ្ញៀវទេសចរអាចសម្រាកលំហែកាយក្នុងខ្ទះ និងអាចកុម្ម៉ង់អាហារ និងភេសជ្ជៈគ្រប់ប្រភេទយកមកពិសាបានតាមតម្រូវការភ្ញាមៗផងដែរ។ លើសពីនេះទៀត ភ្ញៀវទេសចរអាចជិះទូកត្នោត ទូកក្តារបីសន្ទឹកអុំកម្សាន្តលេង និងស្ទូចត្រីធម្មជាតិក្នុងព្រែកត្នោត ពិសេសគយគន់មើលព្រះសុរិយារៀបអស្តង្គត ព្រមទាំងអាចថតផ្តិតយករូបភាពស្អាតៗ ជាច្រើនទុកជាអនុស្សាវរីយ៍នៅទីនោះផងដែរ៕



# 21 ខេត្ត តាកែវ

## 1.1 រមណីយដ្ឋានទេសចរណ៍ភ្នំដា

សក្តានុពលទេសចរណ៍៖ ភ្នំដាជារមណីយដ្ឋានទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ បំរើឱ្យភ្ញៀវទេសចរណ៍មកធ្វើការសិក្សាស្រាវជ្រាវ ស្វែងយល់អំពីប្រវត្តិសាស្ត្រនៃការកកើតឡើងដំបូងបង្អស់នូវទឹកដីប្រទេសកម្ពុជាក្នុងសម័យកាលដ៏យូរលង់ណាស់មកហើយៗ រីឯទេសភាពជុំវិញភ្នំក៏មានសម្រស់គួរឱ្យគយគន់ នារដូវវស្សាព័ទ្ធជុំវិញទៅដោយទឹកទឹកធំល្ហល្ហេវដូចជាសមុទ្រ ហើយនៅរដូវប្រាំងគឺជាវាលស្រែធំល្វឹងល្វើយមើលដាច់កន្ទុយភ្នែក។
សកម្មភាពទេសចរណ៍៖ ដើម្បីទៅសម្រាកលំហែកាយ កម្សាន្តសប្បាយ ភ្លក្សរសជាតិម្ហូបអាហារក្នុងតំបន់ និងការសិក្សាស្រាវជ្រាវ។

ទីតាំង៖ រមណីយដ្ឋានទេសចរណ៍ភ្នំដា ស្ថិតនៅខាងកើតទីរួមខេត្តតាកែវ ក្នុងភូមិព្រៃកតាផ ឃុំគោកធ្លក ស្រុកអង្គរបូរី ខេត្តតាកែវ
ចម្ងាយ៖ មានចម្ងាយ ២៥គីឡូម៉ែត្រតាមផ្លូវទឹក និង៦៥គីឡូម៉ែត្រតាមផ្លូវគោកពីទីរួមខេត្តតាកែវ។
មធ្យោបាយ៖ ភ្ញៀវទេសចរណ៍អាចធ្វើដំណើរដោយកង់ ម៉ូតូ រថយន្តតាមផ្លូវគោក និងទូក អូប័រតាមផ្លូវទឹក។



## 1.2 ប្រវត្តិរមណីយដ្ឋានទេសចរណ៍ភ្នំដា

ប្រាសាទភ្នំដាកសាងនៅលើកំពូលភ្នំដា មានកម្ពស់៤០ម៉ែត្រ ប្រាសាទនេះបែមុខទៅទិសខាងជើងសំដៅទៅរករាជធានីនគរភ្នំ ដែលទីតាំងស្ថិតនៅស្រុកអង្គរបូរីសព្វថ្ងៃ។
ប្រាសាទនេះកសាងអំពីឥដ្ឋ ថ្មបាយក្រៀម និងថ្មភក់ ជារាងការ៉េ ជ្រុងនីមួយៗមាន១២ម៉ែត្រ និងមានកម្ពស់១៨ម៉ែត្រ ពុំមានជណ្តើរទេ មានទ្វា៣ជាទ្វាបញ្ឆោតនិងទ្វា៤ទ្វាពិតនៅជញ្ជាំងខាងជើងហើយជញ្ជាំងក្រាសខុសប្លែកពី

ប្រាសាទនានា។ ប្រាសាទភ្នំដាពុំមានរបង(កំពែងឬកំផែង)ព័ទ្ធជុំវិញទេ។ នៅខាងក្នុងមានតាំងលិង្គព្រះឥសូរតាំងពីសម័យសាងសង់ប្រាសាទសម្រាប់ជាទីសក្ការៈបូជា។ ប្រាសាទនេះកសាងឡើងក្នុងសតវត្សទី៦ក្នុងរជ្ជកាលព្រះបាទរុទ្រវរ្ម័នជាក្សត្រចុងក្រោយក្នុងសម័យអាណាចក្រភ្នំ ដើម្បីឧទ្ទិសដល់ព្រហ្មញ្ញសាសនា ដោយសារតែប្រាសាទភ្នំដាមានអាយុកាលចាស់តាំងពីសតវត្សទី ៦ នោះទើបក្នុងរជ្ជកាព្រះបាទសូរ្យវរ្ម័នទី១ ជួសជុលឡើងវិញ(សតវត្សទី១១) ដោយកត់សម្គាល់ឃើញផ្តេរ និងសសរពេជ្រប្រហាក់ប្រហែលគ្នា និងរចនាបទឃ្លាំង។ ដោយឡែកផ្តេរសសរពេជ្រត្រូវយកទៅរក្សាទុកនៅសារៈមន្ទីរអង្គរបូរីតាំងពីឆ្នាំ១៩៩៩។ ប្រាសាទភ្នំដាគឺជាប្រាសាទទោល។



## 1.3 ភ្នំតាម៉ៅ



ភ្នំតាម៉ៅជារម្មណីយដ្ឋានចំរុះមានប្រាង្គប្រាសាទ ព្រៃភ្នំធម្មជាតិ និងជាសួនសត្វដ៏ធំក្នុងប្រទេសកម្ពុជា។ តំបន់នេះមានផ្ទៃដី ១២០០ ហិចតា ដែលគេអោយឈ្មោះថា តំបន់ផ្ទៃដីការពារព្រៃឈើ។ ក្នុងចំនោមផ្ទៃដី ១២០០ហិចតានេះ ផ្ទៃដីចំនួន ១២០០ហិចតា ត្រូវបាននាយកដ្ឋានរុក្ខាប្រមាញ់ រៀបចំដាំដើមឈើ និងរៀបចំសួនសត្វ ដែលមានផ្ទៃដី ៧០ហិចតា។ ផ្ទៃដី ៧០ហិចតានេះ

រួមមាន ភ្នំចំនួន៥ គឺ ភ្នំតាម៉ៅ ភ្នំថ្មដុះ ភ្នំផ្តៅពន្ធ ភ្នំឆយ និងភ្នំបាំង។ ក្នុងចំណោមភ្នំទាំង ៥ នេះមានភ្នំពីរមានប្រាសាទបុរាណគឺប្រាសាទតាម៉ៅ (ភ្នំតាម៉ៅ) ប្រាសាទថ្មដុះ (ភ្នំថ្មដុះ) ។ ភ្ញៀវជាតិនិងអន្តរជាតិដែលមកលេងឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ មិនដែលរំលងទស្សនាសត្វកម្រ ៦ ប្រភេទមានដូចជា ពោះថ្វាន់ ក្រពើ ខ្លា តោ ដំរី និងខ្លាឃ្មុំ។ សត្វទាំងនេះមានប្រជាប្រិយភាពខ្លាំង និងស្ថិតនៅក្នុងបញ្ជីលើគេដែលទាក់ទាញភ្ញៀវទេសចរច្រើនបំផុតទស្សនា ពេលមកកម្សាន្តនៅសួនឧទ្យានភ្នំតាម៉ៅ។ មូលហេតុដែលនាំឲ្យសត្វទាំងនោះ ក្លាយជាសត្វពេញនិយមជាងគេ ត្រូវបានលោក គុយ តុង អនុប្រធានគ្រប់គ្រងឧទ្យានសួនសត្វភ្នំ តាម៉ៅ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃប្រាប់ថា ដោយសារសត្វទាំងនោះពពួកសត្វកម្រ ហើយសត្វមួយចំនួនក៏មានភាពឈ្លាសវៃអាចសំដែងសមត្ថភាពពិសេសសម្រាប់ភ្ញៀវទស្សនាផងដែរ៕

ទីតាំង

ភ្នំតាម៉ៅមានទីតាំងស្ថិតនៅភូមិត្រពាំងសាប ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ មានចំងាយ ៤០គ.ម តាមផ្លូវជាតិលេខ ២ពីរាជធានីភ្នំពេញ បត់ស្តាំ ៥គ.ម តាមផ្លូវលំ ដោយប្រើរយៈពេលធ្វើដំណើរតាមរថយន្តអស់ ៤៥នាទី។








# 22 ខេត្តត្បូងឃ្មុំ

## 1.1 សហគមន៍ទេសចរណ៍

ទីតាំងនៅភូមិ ជីរោទិ៍ក្រោមទី២ ឃុំជីរោទិ៍ទី១ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ មានចម្ងាយផ្លូវ ៤០គីឡូម៉ែត្រ ពីទីរួមខេត្តត្បូងឃ្មុំ។ អង្គការបណ្តុះបណ្តាលថ្នាក់មូលដ្ឋាន (Organization For Basic Training) ហៅកាត់ថា OBT ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០០៧ ដោយមានការចូលរួមពីសប្បុរសជន និងសហគមន៍ជីរោទិ៍ ក្នុងគោលបំណងលើកស្ទួយវិស័យអប់រំ និងជីវភាព សុខមាលភាពរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ឱ្យកាន់តែប្រសើឡើង និងចូលរួមរំលែកបន្ទុករបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។ អង្គការនេះត្រូវបានចុះញ្ជីទទួលស្គាល់ត្រឹមត្រូវដោយក្រសួងមហាផ្ទៃ តាមរយៈលិខិតលេខ ១៥៤១/ស.ជ.ណាចុះថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០០៩ និងត្រូវបានបង្កើតជាទេសចរណ៍ដើម្បីសហគមន៍ជីរោទិ៍ (Tourism For Chiro Community) នៅក្នុងឆ្នាំ២០១៧ ដោយមានការទទួលស្គាល់ជាផ្លូវការពីមន្ទីរទេសចរណ៍ខេត្ត និងរដ្ឋបាលខេត្តត្បូងឃ្មុំ តាមរយៈលិខិត ៧៣៤/១៧ លសខតឃ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់រដ្ឋបាលខេត្តត្បូងឃ្មុំ។ក្នុង១ខែៗអង្គការទទួលភ្ញៀវទេសចរបរទេសមកកំសាន្ត និងស្នាក់នៅ HOME STAY និង BUNGALOW មានចំនួនប្រហែលពី៦០ទៅ១០០នាក់សំរាប់រដូវកាលដែលមានភ្ញៀវទេសចរច្រើន និងទេសចរក្នុងស្រុកដែលបានមកកំសាន្ត ក្រុងឬស្សី(ចំការឈូករតន៍) ប្រហែលពី ៥០០នាក់ក្នុងថ្ងៃធម្មតា និង ប្រហែលជាង ១០០០នាក់នៅថ្ងៃសៅរ៍ អាទិត្យ និងថ្ងៃបុណ្យជាតិ។



## 1.2 រមណីយដ្ឋានអន្លង់ជ្រៃ

រមណីយដ្ឋានអន្លង់ជ្រៃ ដែលគេនិយមហៅថា"ភូមិសម្តេច ហេង" ត្រូវបានអ្នកទេសចរជាតិកំពុងចាប់អារម្មណ៍ និងនាំក្រុមគ្រួសារ មិត្តភក្តិ ញាតិសន្តាន ទៅលេងកម្សាន្ត និងញ៉ាំអាហារពេលថ្ងៃត្រង់ ថែមទាំងលេងទឹកនៅទំនប់បង្ហៀរទឹកក្នុងភូមិនេះយ៉ាងសប្បាយរីករាយថែមទៀតផង។ ភូមិអន្លង់ជ្រៃ បើថ្ងៃធម្មតាមិនសូវមានភ្ញៀវទេសចរទៅលេងកម្សាន្តនៅឯរមណីយដ្ឋានមួយនេះទេ តែបើថ្ងៃចុងសប្តាហ៍ សៅរ៍ អាទិត្យ ឬថ្ងៃបុណ្យទានវិញ រកតែកន្លែងអង្គុយលេងស្ទើរតែគ្មានផង។នៅទីនោះមានទំនប់ទឹកយ៉ាងធំសម្រាប់លេងកម្សាន្ត និងមាន បរិយាកាសបរិសុទ្ធខ្យល់អាកាសធម្មជាតិតាមបែបស្រុកស្រែចម្ការ និងមានលក់ម្ហូបអាហារឈ្ងុយឆ្ងាញ់ដូចជា មាន់ដុត កង្កែបបោកសាច់គោអាំង ត្រីអាំង និងម្ហូបអាហារជាច្រើនបែបតាមរបៀបអ្នកជនបទជាច្រើនមុខទៀត។រមណីយដ្ឋាន អន្លង់ជ្រៃមានទីតាំងស្ថិតនៅក្នុងភូមិអន្លង់ជ្រៃ(ភូមិសម្តេច ហេង) ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ បើយើងធ្វើដំណើរចេញពីភ្នំពេញ បត់តាមស្ពានព្រែកតាមាក់ រហូតដល់រង្វង់មូលស្វាយអន្ទរ រួចបន្តដំណើរប្រមាណ ៤០ គីឡូម៉ែត្រទៀត ដោយបត់ទៅទិសខាងកើតឆ្ពោះទៅកាន់ស្រុកពញាក្រែក នោះនឹងឃើញរមណីយដ្ឋានអន្លង់ជ្រៃ ដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៨ នេះតែម្តង។



## 1.3 តួប៉មទន្លេបិទ

តួប៉មទន្លេបិទស្ថិតនៅត្រើយខាងកើតទន្លេមេគង្គ ខាងឆ្វេងដៃនៃស្ពានគីហ្សូណា។ តួប៉មនេះចាប់ផ្តើមកសាងតាំងពីជំនាន់អាណានិគមនិយមបារាំង ដោយធ្វើអំពីឥដ្ឋតាន់អស់រយៈពេលចំនួន២ឆ្នាំទើបបានហើយជាស្ថាពរ។ ក្នុងសាងសង់បារាំងបានបញ្ជូនអ្នកទោសខ្មែរមួយចំនួនពីកំពង់ចាម ដើម្បីមកជួយការសាងសង់។ តួប៉មមានកំពស់៣៨ម៉ែត្របាទក្រោមមានរាងចតុកោណកែងមានបណ្តោយប្រវែង៩ម៉ែត្រនិងមានទទឹងប្រវែង៧.៥០ម៉ែត្រ ហើយមានទ្វារសម្រាប់ចេញចូលចំនួនពីរគឺខាងកើតមួយនិងខាងលិចមួយ។ បុព្វហេតុនៃការសាងសង់តួប៉មនេះតាមចម្លើយរបស់អ្នកស្រុកដែលមានវ័យចំណាស់មួយចំនួនបានបញ្ជាក់អះអាងថា ការដែលបារាំងកសាងតួប៉មនេះឡើងគឺដើម្បីរក្សាសន្តិសុខនៅទីកន្លែនោះហើយក៏ជាកន្លែងសម្រាប់ឃ្លាំមើលគ្រែងកម្មករឬអ្នកស្រុកលួចដឹកជ័រកៅស៊ូយកទៅឱ្យឈ្មួញក្រៅ។







# 23 ខេត្តព្រះសីហនុ

## 1.1 រមណីយដ្ឋានអន្លង់ជ្រៃ

ខេត្តព្រះសីហនុជាខេត្តមួយស្ថិតនៅភាគនីរតីនៃប្រទេសកម្ពុជាដែលសំបូរទៅដោយតំបន់ទេសចរណ៍សំរាប់ដើរកំសាន្ត ដែលមានកន្លែងទេសចរណ៍សំខាន់ៗចំនួន ៦កន្លែង ដែលនៅក្នុងនោះមានតំបន់ ឆ្នេ ៤ កន្លែង តំបន់កោះ ១ កន្លែង និង រមណីដ្ឋាន ធម្មជាតិ និង វប្បធម៌ ដែលមានទីតាំងនៅក្នុង ខេត្តព្រះសីហនុមាន៖



## 1.2 រមណីដ្ឋានឆ្នេរអូរឈើទាល

**ទីតាំង**

រមណីយដ្ឋានឆ្នេរអូរឈើទាល ស្ថិតនៅខេត្តព្រះសីហនុក្រុងព្រះសីហនុ ប្រទេសកម្ពុជា។

**ទិដ្ឋភាពទូទៅ**

រមណីយដ្ឋានឆ្នេរអូរឈើទាល ជាតំបន់ទេសចរណ៍មួយ គួរជាទីចាប់អារម្មណ៍បំផុតរបស់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ។ ជារៀងរាល់ឆ្នាំ តែងតែមានភ្ញៀវទេសចរណ៍មក កំសាន្តនៅទីនេះ ច្រើនកុះករបំផុត មិនថាពេលមានបុណ្យទានឬមានកម្មវិធីអ្វីក៏ដោយ។ឆ្នេរអូរឈើទាល ជាឆ្នេរដែលវែងជាងគេ ដោយលាតសន្ធឹងផ្នែកខាងជើងពីរង្វង់មូលតោពីរ រហូតដល់ខាងត្បូងដល់ភ្នំដំណាក់ស្តេច ជាប់នឹងឆ្នេរអូត្រេះ និងអមដោយឆ្នេរខ្សាច់មានពណ៌សក្បោះ មានជម្រៅទឹករាក់ ហើយនេះក៏ជាហេតុផលដែលធ្វើឱ្យឆ្នេរនេះសម្បូរមនុស្សលេងទឹកច្រើនផងដែរ។



## 1.3 ឆ្នេរសុខា

ឆ្នេរសុខា មានទីតាំងស្ថិតនៅ ខេត្តព្រះសីហនុ និងមានចម្ងាយប្រហែល ~2km ពីរង្វង់មូលតោពីរ។ ឆ្នេរសុខា ស្ថិតនៅក្នុងប្រភេទ៖ ឆ្នេរសមុទ្យ។ រីឯចំណុចសំខាន់ៗនៅ ឆ្នេរសុខា មានដូចជា៖ លេងទឹកឬហែលទឹក, គយគន់ថ្ងៃលិច, ជិះទូក, ឆ្នេរសមុទ្រ និងចំណុចផ្សេងៗទៀត។

ឆ្នេរសុខាលាតសន្ធឹងវែងបន្តពីឆ្នេរអូរឈើទាល ប៉ុន្តែទឹកមាន លក្ខណៈ ជ្រៅ មានឆ្នេរខ្សាច់ ពណ៌សរ រីឯ ទឹករលក សមុទ្រវិញ មានលក្ខណៈ ខ្លាំងជាងឆ្នេរអូរឈើទាល។

សព្វថ្ងៃ នេះ មានភ្ញៀវ ទេសចរណ៍យ៉ាង ច្រើនកុះក៏ ជាពីសេសភ្ញៀវ អន្តរជាតិ ព្រោះឆ្នេរ នេះសព្វថ្ងៃត្រូវ បាន វិនិយោគទុន ដោយក្រុមហ៊ុនសុខាអូតែល របស់ លោកឧញ្ញាសុខគង់។ នៅឆ្នេរសុខា នេះលោកអ្នកអាចងូត ទឹក លេង ដេក សំដិល លើវាល ខ្សាច់ រឺក៏អាចជិះទូកលេងក៏បាន លើសពីនេះ ទៅទៀត លោកអ្នកអាចជិះ ទូកទៅលេង កោះជាច្រើននៅ ក្បែរៗឆ្នេរ នោះបាន ផងដែរ។ រីឯសំរាប់ ភ្ញៀវ ទេសចរណ៍ដែល មកពីទីឆ្ងាយ អាចស្នាក់ នៅក្នុង សណ្ឋាគារសុខាក៏បានដែរ។







## 1.4 កោះពស់

*ទីតាំង*

*កោះពស់ មានទីតាំងស្ថិតនៅ ខេត្តព្រះសីហនុ និងមានចម្ងាយប្រហែល ~8km ពីរង្វង់មូលតោពីរ។*



*ទិដ្ឋភាពទូទៅ*

*កោះពស់ ស្ថិតនៅក្នុងប្រភេទរមណីយដ្ឋាន កោះ និងឆ្នេរសមុទ្យ។ សម្រាប់ចំណុចសំខាន់ៗ ក៏ដូចជាភាពទាក់ទាញនៃរមណីយដ្ឋានកោះពស់ដែលអាចធ្វើអោយភ្ញៀវទេសចរមានចំណាំអារម្មណ៍នោះ មានដូចជា៖ លេងទឹកឬហែលទឹក, គយគន់ថ្ងៃលិច, ជិះទូក, ឆ្នេរសមុទ្រ និងចំណុចផ្សេងៗទៀត។កោះពស់ ជាកោះមួយនៅដាច់ពីឆ្នេរសមុទ្រដទៃទៀត អ្នកទេសចរទៅលេងតំបន់នោះ ភាគច្រើនជាក្រុមភ្ញៀវដែលវិចខ្ចប់ម្ហូបអាហារទៅជាមួយផង។ សម្រាប់ការធ្វើដំណើរដើម្បីទៅដល់ទីតាំងនៃរមណីយដ្ឋានកោះពស់ ភ្ញៀវទេសចរមានភាពងាយស្រួល ពីព្រោះមិនមានការធ្វើដំណើរថ្មើរជើង និងធ្វើដំណើរឆ្លងទឹក រឺក៏ជិះទូកឡើយ។ ចំពោះចំណតរថយន្តវិញ ភ្ញៀវទេសចរអាចធ្វើការចតដោយផ្ទាល់នៅរមណីយដ្ឋានបានថែមទៀតផង។*

*សម្រាប់កន្លែងអង្គុយលំហែរកាយវិញ រមណីយដ្ឋានកោះពស់ គឺមានខ្សឹសអង្គុយ រឺក៏តូបអង្គុយជាច្រើនសម្រាប់ភ្ញៀវទេសចរ ហើយក៏មានសេវាកម្មទទួលកម្មង់អាហារផ្ទាល់ពីទីនោះផងដែរ។ ក្រៅពីនេះ រមណីយដ្ឋានកោះពស់មានអាហារដ្ឋាន ប៉ុន្តែសម្រាប់កន្លែងកម្មង់អាហារ រឺកន្លែងលក់អាហារ និងភោជនីយដ្ឋានពុំទាន់មាននៅឡើយទេ។ សម្រាប់កន្លែងស្នាក់នៅ រមណីយដ្ឋានកោះពស់មានប៊ីងហ្គាឡូ ប៉ុន្តែសម្រាប់ផ្ទះសំណាក់ និងសណ្ឋាគារពុំទាន់មាននៅឡើយទេ។*





សម្បត្តិបេតិកភណ្ឌជាតិគឺជាកេរ្តិ៍ដំណែលរបស់ដូនតាដែលមិនអាចកាត់ថ្លៃបាន